PTI0075

# សម្ភាសន៍ជាមួយឈ្មោះ សួន សែម ភេទប្រុស អាយុ៦០ឆ្នាំ

រស់នៅភូមិដីក្រហម ឃុំអន្ទុងរាប ស្រុកវាលវែង ខេត្តពោធិ៍សាត់

មុខងារសម័យខ្មែរក្រហមៈ ទាហានខ្មែរក្រហម

មុខងារបច្ចុប្បន្នៈ ធ្វើចំការ

សម្ភាសន៍ដោយៈ សោម ប៊ុនថន

សម្ភាសន៍ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១១

សរុបទំព័រៈ ៤៧

០១:៥៧:៣៥

សែមៈ បានវៃខ្មែរទៅ ហើយអាមេរិចកាំងគេថាគេវៃតែយៀកកុងកាលហ្នឹង ឯយៀកកុងគេថាអត់វៃខ្មែរទេគេវៃតែពួកអាធីវទេ ប៉ុន្តែដល់ពេលនេះទៅគេយកទឹកដីខ្មែរយើងធ្វើជាកន្លែងទីលានប្រយុទ្ធគ្នា អាមេរិចកាំងវាទម្លាក់តាំងពីគ្រាប់បេ៥២ វាថាអត់វៃខ្មែរទេតែគេទម្លាក់យៀកកុង ។

ប៊ុនថនៈ ចូលដល់ដីខ្មែរ ។

សែមៈ រស់នៅដីខ្មែរហ្នឹង កាលហ្នឹងខ្ញុំនៅកងទ័ព តាមពិតកកើតនៅក្មេងដែរ តែដល់ផុតពីហ្នឹងមកបានមានកិច្ចព្រមព្រាងគ្នាទៅ នៅសូរ្យីណែវហ្នឹងគេថាអាមេរិចកាំងហ្នឹងគេអត់វៃខ្មែរទេ ហើយយួនក៏គេថាអត់វៃខ្មែរទេ អញ្ចឹងបានន័យថាគេព្រមព្រាងគ្នាថាអាមេរិចកាំងគេឈប់វៃហើយ គេនឹងដកយន្តហោះចេញពីដីខ្មែរ គេឈប់វៃដល់ព្រៃ៥២អញ្ចឹង អញ្ចឹងបានកងទ័ពខ្មែរយើងកកើតឡើង មានកងពល ដើមហេតុដំបូងគឺ ម៉េត យើងនៅសំឡូតហ្នឹង គាត់ធ្លាប់ជាកងពលហើយមានតាៗមួយចំនួនដែលអ្នក ដូច តានួន ជា តាអីអត់ដឹងឈ្មោះទេបើឈ្មោះគឺឈ្មោះ តាខៀវ សំផន ហ្នឹងបានព្រួ កាលសម័យហ្នឹងវាមានគោនឹម គោយន្តអញ្ចឹងដែរណា៎ តាមពិតតាខៀវ សំផន ហ្នឹងគាត់ជាតំនាងរាស្ត្រ គេហៅថាស្រុកកណ្ដាលស្អឹងយើងហ្នឹង ចេញមក ។

ប៊ុនថនៈ ខាងស្អាងខាងអីហ្នឹង ។

សែមៈ ប៉ុល ពត អីអត់មានឈ្មោះទេ ដល់ពេលអញ្ចឹងទៅបានសម្ដេចសីហនុហ្នឹងរៀបរយថាផលូវកូនចៅខំតស៊ូយកទឹកដីយើងវិញ គាត់មកសម្ភោធនៅអង្គរនៅអីអញ្ចឹងណា៎ គាត់មកសម្ភោធហ្នឹងឲ្យកូនចៅខំតស៊ូឡើង អាហ្នឹងសម័យហ្នឹង ដល់ពេលផុតពីហ្នឹងមកខំតស៊ូវាមិនដឹង

ស មិនដឹងខ្មៅ មិនដឹងជាស្អីណា៎ ហើយការពិតជាអ្នករងគ្រោះ គេថាទៅចេះតែធ្វើៗទៅតាមគេអញ្ចឹងទៅ រហូតមកដល់រំដោះឆ្នាំ៧៥ ដល់ពេលរំដោះឆ្នាំ៧៥ហ្នឹងខ្ញុំនៅកងទ័ពដដែលអត់មានទៅណាទេ ប៉ុន្តែរំដោះបានប៉ុន្មានទេ ប្រហែលជាមួយអាទិត្យបានទៅព្រំដែន អញ្ចឹងរវាងវៀតណាមហើយនឹងខ្មែរក្រហមគឺតាំងពីឆ្នាំ៧៥មកនោះក៏មានបញ្ហាល្អក់កករវាងឆ្នាំ៧៣ ហើយកងទ័ពហ្នឹងគឺចាប់ផ្តើមរំលែកហើយ អ្នកដែលនៅខាងលិចហ្នឹងគឺមកការពារព្រំដែនខាងលិចទៅ ហើយអ្នកនៅខាងកើតគឺទៅការពារព្រំដែនខាងកើតទៅ ខាងត្បូងនោះការពារព្រំដែនខាងត្បូងទៅ ហើយខ្ញុំទៅនៅការពារព្រំដែនទៅ។

ប៊ុនថនៈ ពូនៅខាងណា?

សែមៈ ខ្ញុំនៅខាងកំពង់ចាម។

ប៊ុនថនៈ ខាងបូរពា៌?

សែមៈ មិនមែនបូរពា៌ទេ នៅខាងកំពង់ចាម ប៉ុន្តែខាងនេះទន្លេ។

ប៊ុនថនៈ ម្ខាងទន្លេ?

សែមៈ បាទ!

ប៊ុនថនៈ ភូមិភាគកណ្តាលវិញ?

សែមៈ បាទ! ភូមិភាគកណ្តាល ប៉ុន្តែកាលហ្នឹងខ្ញុំអត់មានបានជាប់ជាមួយកែវ ពក អីទេ តែគ្រាន់តែខ្ញុំបានមកនៅកងទ័ពស្រួចហើយ ព្រោះការពិតគេហៅថាអាយុវាច្រើនកាលហ្នឹង អញ្ចឹងកាលហ្នឹងគេរៀបចំកងទ័ព បើគិតទៅតាមដែលចាំនោះអត់មានច្រើនទេ បើគិតទៅមានតែ១២កងពលទេ កងពលអតីតខ្មែរក្រហមហ្នឹងណា៎ អញ្ចឹងចែកទៅ ទៅខាងបង សារឿន ២២១នោះទៅខាងរតនៈគិរីទៅ កងស្រួច។

ប៊ុនថនៈ ឈ្មោះ សារឿន?

សែមៈ ឈ្មោះ សារឿន តែឥលូវស្លាប់ហើយ មិនដឹងមានរឿងអីទេព្រោះខ្ញុំមិនច្បាស់ដែរ ព្រោះគាត់នៅខាងលង្វែក ហើយដល់ពេលហ្នឹងមកក៏.. ខ្ញុំតាមពិតបែកពីអង្គភាពដោយសាររបួស របួសទៅវៃនៅខាងកើត វៃនៅយើងស្នួល ដល់ពេលត្រូវរបួសមកគេដាក់យន្តហោះមក មកសម្រាក ហើយក៏បានជួបស្រីៗខ្ញុំហ្នឹងគេធ្វើពេទ្យ។

ប៊ុនថនៈ សម្រាកនៅពេទ្យរុស្សីមែនពូ?

សែមៈ សម្រាកនៅពេទ្យរុស្សីកាលហ្នឹង កាលហ្នឹងគេដាក់នៅពេទ្យរុស្សីហ្នឹងហើយ គេហៅមិត្តភាពសុវៀតខ្មែរហ្នឹង។

ប៊ុនថនៈ អញ្ចឹងពូចូលដំបូងនៅខាងភូមិភាគកណ្តាលហ្នឹង ដូចជាកើតក្រោយទេពូ កងទ័ព?

សែមៈ ភូមិភាគកណ្ដាលហ្នឹងដែលកើត ចាំមើលកាលហ្នឹងតាមដែលខ្ញុំដឹងគេរៀបចំ ដល់ពេលរំដោះ ឡើងគេចែកគ្នា ចាំមើល កងទ័ពភូមិភាគកណ្ដាលនឹងភូមិភាគបូព៌ា នេះមនុស្សវាច្រើន អញ្ចឹងឲ្យកងទ័ពទាំងពីផ្នែកហ្នឹងទៅជាថ្មើរជើង ប៉ុន្តែដល់ពេលក្រោយមកម៉ុចក្រិចក្រអីធ្វើ បញ្ហាសើរើអំពីរឿងអតីតខ្មែរក្រហមហ្នឹងទៅ អញ្ចឹងគេចាប់ផ្ដើមប្រទូសប្រទះគ្នា ទាំងចក្រី អីហ្នឹង ដល់ពេលហ្នឹងទៅវាទាក់ទិន ចាំមើលទាក់ទិនជាមួយ តាសួង ជាមួយ បងសួងអីហ្នឹង កងពលដែរ កងពល៤៥០ កងពល៣១០អញ្ចឹងទៅ ដល់ពេលអញ្ចឹងគេថាក្បត់ទាំងអស់ ទៅ មេៗអស់ហ្នឹង ដល់ពេលក្បត់អញ្ចឹងទៅវាប្រទាក់ប្រទិស ហើយខាងចក្រីហ្នឹងក៏ចាប់ ផ្ដើមរំលាយហើយ ហើយដកគេច្រឡូកគ្នាហើយពេលហ្នឹង ហើយគេយកកងទ័ពផ្នែកពីខាង នារតីមកដាក់ខ្លះទៅ មេខ្លះទៅ កូនខ្លះទៅប្រវល់គ្នាអត់ច្បាស់លាស់ទៀតទេ ។

ប៊ុនថនៈ អញ្ចឹងចក្រីគាត់អ្នកដកមែនពូ?

សែមៈ មិនមែនទេ មិនដឹងជាអ្នកណាបញ្ជាមក កាលជំនាន់ហ្នឹងគេហៅបក្ស បក្សខាងលើៗមិនដឹង ជាអ្នកណា បញ្ជាអីយ៉ាងម៉េចខ្ញុំមិនសូវចាំ ខ្ញុំមិនសូវច្បាស់ទេព្រោះនៅតែកងទ័ព កាលហ្នឹង យើងយុទ្ធជនធម្មតាទេណា៎ បើមានតួនាទីអាចដឹងខ្លះ ប៉ុន្តែគ្រាន់តែថាអង្គភាពរបស់ខ្ញុំបើអ្នក មានតួនាទីគេចាប់ទាំងអស់ ។

ប៊ុនថនៈ ពីណាខ្លះពូដែល..?

សែមៈ អង្គភាពមាន បងសួង ក៏គេចាប់ អនុ តាំងពីវរៈសេនាតូចឡើងទៅគេចាប់ទាំងអស់ អនុ សេនាធំគេចាប់ទាំងអស់ ហើយចាប់ហ្នឹងបើតាមព្តដំណឹងគេថាយកទៅដាក់គុកព្រៃសទាំង អស់ហ្នឹងតាមមើល ដូចជាអត់មានសល់ទេ ។

ប៊ុនថនៈ ចាប់ហ្នឹងពូដឹងទេ?

សែមៈ ដឹងដែរ ពេលដែលគេចាប់យកទៅហ្នឹង ពេលគេចាប់យកទៅគេគ្រាន់ថា គេផ្សព្វផ្សាយគេ ថាក្បត់ហ្នឹងបក្ស ហើយគេយកទៅហ្នឹង តែមិនដឹងយកទៅណាមកណាទេខ្ញុំអត់បានដឹងដែរ ប៉ុន្តែដល់ក្រោយមកខ្ញុំទទួលមេថ្មីទៅ ក៏សម្រេចឲ្យចុះទៅព្រំដែនទៅ ទៅទាំងអញ្ចឹងទៅ ហើយអត់ដឹងណាដឹងណីទេចេះតែដើរទៅ មួយថ្ងៃៗចេះតែដើរល្បាតការពារព្រំដែនខ្លាចជួប បញ្ហាអី ដល់ពេលដឹងគឺដឹងពេលដែលមកសម្រាកនៅពេទ្យ ហើយដើរជាមួយប្រជាជនហ្នឹង បានដឹង ដឹងថាជីវភាពប្រជាពលរដ្ឋអីគាត់អត់បាយអត់ទឹក អាហ្នឹងដឹងអញ្ចឹងណា៎ ដឹងដោយ សារគាត់និយាយគាត់អី ប្រហែលជាពួកកងទ័ពអត់មានដឹងទេ ព្រោះដាច់រយៈគ្នា អត់មាន យើងនៅជាមួយប្រជាពលរដ្ឋទេ នៅការពារតែព្រំដែន យើងអត់មានដឹងអីទេ ។

ប៊ុនថនៈ ពូចូលជំបូងហ្នឹង ពូចូលនៅភូមិឃុំហ្នុង?

សែមៈ កាលហ្នឹងចូលនៅក្នុងភូមិ ក្នុងភូមិហ្នឹងកាលហ្នឹងគេឃោសនា ការពិតនៅឆ្នាំ៧០ហ្នឹងគេធ្វើរដ្ឋប្រហារ ដល់ពេលគេធ្វើរដ្ឋប្រហារគេប្រកាស កាលហ្នឹងនៅក្នុងភូមិខ្ញុំហ្នឹងគេមានសម្លាប់មនុស្សច្រើនដែរកាលហ្នឹង បើតាមគិតទៅគេហៅថាខ្មែរក្រហមពីមុនមកហ្នឹង អញ្ចឹងគេសម្លាប់មនុស្សមានផ្លូវ៥នាក់ មានផ្លូវ២០នាក់ម៉ាជួរស្តន់ហ្នឹង ដែលគេហៅព្រៃកុងហ្នឹង គេសម្លាប់មនុស្សច្រើន តែមិនដឹងជាអ្នកណាសម្លាប់ ដល់សាកសួរទៅគឺតាមមើលកាលពីមុនមក បើតាមខ្ញុំគិតថា អាចសម្តេចសីហនុអីឬក៏បំផ្លាញខ្មែរក្រហមអញ្ចឹងណា៎ បើតាមខ្ញុំយល់ដល់ក្រោយមកមនុស្សនៅហ្នឹងទៅគេចលនាក៏នាំ ការពិតខ្ញុំកាលហ្នឹងដល់អាយុវាត្រូវអញ្ចឹងគេ ភូមិឃុំគេៗចាត់តាំងរៀបរយឲ្យយើងចូលហ្នង។

ប៊ុនថន: ចូលនៅភូមិឃុំហ្នឹងហ្នង?

សែមៈ បាទ! ចូលនៅភូមិឃុំហ្នឹង។

ប៊ុនថនៈ ពូកាលហ្នឹងពូនៅភូមិអីដែរ?

សែមៈ ខ្ញុំនៅភូមិឈើទាល ឃុំផ្តៅជុំ។

ប៊ុនថនៈ ស្រុកអីដែរ?

សែមៈ ស្រុកជើងព្រៃ។

ប៊ុនថនៈ ខេត្តកំពង់ចាម?

សែមៈ ខេត្តកំពង់ចាម។

ប៊ុនថនៈ អញ្ចឹងពូចូលដំបូងគឺចូលនៅភូមិហ្នឹងហ្នង?

សែមៈ បាទ!

ប៊ុនថនៈ គេជ្រើសរើស មានច្រើនទេលោកពូ?

សែមៈ កាលខ្ញុំមកហ្នឹងមានគ្នា៨នាក់ មួយវគ្គៗអញ្ចឹងណា អញ្ចឹងក្នុងហ្នឹងកងតំណាងជនហ្នឹងគេថាឧទាហរណ៍ថា ផលូវឈ្មោះ ក ឈ្មោះ ខ អញ្ចឹងយើងមានថ្វីដៃ ធ្វើការងារល្អអញ្ចឹងគេបញ្ជូនមក គ្រាន់គេប្រាប់ថាផលូវឯងត្រូវចូលទ័ពហើយ ហើយប្រាប់ឪពុកម្តាយអីត្រឹមត្រូវទៅ ទៅលាគាត់ទៅ អាហ្នឹងគេឃោសនាអញ្ចឹង ដល់ពេលយើងចេញដំណើរមក ឧទាហរណ៍ថាផលូវគ្នា៨នាក់ អញ្ចឹងមិនមែននៅក្នុងភូមិហ្នឹងទៀតទេចូលមកកន្លែងសង្កាត់ទៀត ចេញពីសង្កាត់មក មកកន្លែងស្រុក ដល់កន្លែងស្រុកបានគេបញ្ជូនទៅអគ្គភាពបញ្ចូលហ្នង ហើយពេលដែលបញ្ចូលហ្នឹងគេធ្វើវេទការ ហើយមាននិមន្តលោកសូត្រយ័នតោព្រោះព្រំកង់ទ័ពហ្នឹង ព្រោះព្រំកង់ទ័ពធម្មតាអញ្ចឹងទៅ ហើយចាប់ផ្តើមបញ្ចូលតាមអគ្គភាព កាលហ្នឹងគេហៅអនុសេនាតូច អនុសេនាធំ។

ប៊ុនថនៈ អត់មានដាក់លេខទេ?

សែមៈ ដាក់លេខដែរហ្នឹង ខ្ញុំនៅកងពល៤៥០ តែលេខអង្គភាពនោះវាភ្លេចអស់ទៅ វាយូរឆ្នាំហើយ បើតាមគិតទៅវា៤០ប្លាយឆ្នាំជាងហើយ ខ្ញុំអត់សូវចាំទេ គេដាក់លេខ ។

ប៊ុនថនៈ នៅជាមួយពីណាគេលោកពូកាលហ្នឹង?

សែមៈ នៅជាមួយ បងស្ងួន ហ្នឹង តែបងស្ងួន ហ្នឹងតាមមើលគេចាប់ដាក់ព្រៃស ឥលូវស្លាប់ហើយ ដែលថាប្រឆាំងហ្នឹងបក្សហ្នឹង ។

ប៊ុនថនៈ តែតាមពិតដូចថាគាត់ប្រឆាំងទេពូ?

សែមៈ បើតាមមើលខ្ញុំមិនច្បាស់ដែរ តែគ្រាន់តែកាលពេលហ្នឹងគេចាប់ជាខ្សែជាអីហ្នឹង ឧទាហរណ៍ថា បងស្ងួន ហ្នឹងគាត់ធ្លាប់ចូលទ័ពពីឆ្នាំប៉ុន្មាន ហើយមានតួនាទីជាកងពលអញ្ចឹងវាជាប់ទាក់ទិនជាមួយអ្នកណាគេចាប់ជាខ្សែៗហ្នឹង ហើយមិនដឹងការខុសឬត្រូវអីទេ ខ្ញុំវាពិបាកវិនិច្ឆ័យដែរ ព្រោះវាចេះតែចាប់យកទៅហ្នឹងឲ្យតែខ្សែ ព្រោះកាលហ្នឹងគេមានខ្សែគេ គេហៅថាខ្សែប្រព័ន្ធកម្មុយនីស អញ្ចឹងអ្នកដែលបានចូលប្រព័ន្ធកម្មុយនីសនោះ ឧទាហរណ៍ថា តាំងពីអនុសេនាតូច អនុសេនាធំឡើងទៅ ឲ្យតែចូលបក្សហ្នឹងហើយគេស្រាវជ្រាវយកតាមខ្សែបក្សគេហ្នឹងហ្នឹង គេយកទៅ ។

ប៊ុនថនៈ គេចាប់យកទៅជាមួយគ្នាទាំងអស់?

សែមៈ បាទ! ចាប់យកតៗ ប៉ុន្តែគ្រាន់តែមុនហើយនឹងក្រោយ ឧទាហរណ៍ថាវរៈសេនាធំអញ្ចឹងគេចាប់កងពលហើយគេចាប់វរៈសេនាធំ ហើយចាប់អនុសេនាធំតគ្នា គេចេះតែយកទៅតគ្នា ហើយនៅសល់អនុសេនាតូច ប្រធានក្រុមអីធម្មតាអញ្ចឹងទៅ ហើយនៅសល់ហើយគេរើសមេថ្មីមកឲ្យគ្រប់គ្រង ។

ប៊ុនថនៈ គេបញ្ជូលខាងណាមក?

សែមៈ ការពិតបើតាមស្តាប់គេថាខាងនារតី កាលហ្នឹងពីតាកែវយកទៅ យកទៅដឹកនាំនៅហ្នឹងគេបញ្ជូលទៅហើយគ្រប់គ្រង ។

ប៊ុនថនៈ ពូមាននៅចាំឈ្មោះទេពូ អ្នកដែលចូលថ្មីហ្នឹង?

សែមៈ ឥលូវនៅខាងជើង ស្លាប់កងពល តាមមើលតាហ្នឹងប្រហែលជាកូនប្រសាររបស់ តាម៉ុក ឈ្មោះ តាវិន គាត់ហ្នឹងកងពល៤៥០ គាត់ទៅគ្រប់គ្រងនៅហ្នឹង តែដល់ក្រោយមកមានបញ្ហាអញ្ចេះអញ្ចុះ ឮថា តាម៉ុក ហ្នឹងបាញ់ចោលទៅ ព្រោះមនុស្សហ្នឹងវាខូច បើតាមខ្ញុំដឹងខូចស្រីខូចអីបំពាន គាត់ក៏បាញ់តាហ្នឹងចោលទៅ ។

ប៊ុនថនៈ ហើយ តាវ៉ែន ហ្នឹងកូនប្រសារគាត់ដែរ?

សែមៈ	តាវ៉ែន ក៏កូនប្រសារ បងប្អូនគេហ្នឹងប្ដីម៉ែយាយអឿន តាម៉ុកអត់មានកូនប្រុសទេ កូនគាត់សុទ្ធតែស្រី តែដល់ពេលកូនប្រសារគាត់សុទ្ធតែកងពលហ្នឹង គាត់ឲ្យសុទ្ធតែកងពល ។

ប៊ុនថនៈ	កូនគាត់ប៉ុន្មាននាក់ តាម៉ុក?

សែមៈ	មិនដឹងប៉ុន្មានទេ មើល! មានយាយអិច យាយហៀង យាយហ៊ា យាយហ៊ាហ្នឹងប្រពន្ធតាវិន ហ្នឹង ហើយណាណីទៀតទេ ច្រើនណាស់កូនតាម៉ុកហ្នឹង ច្រើនដែរហ្នឹងចាំមិនអស់ទេ ។

ប៊ុនថនៈ	ប៉ុន្ដែ វិន ហ្នឹងថាបាញ់ចោលហ្នឹង តាម៉ុក គាត់បាញ់ផ្ទាល់ឬក៏?

សែមៈ	គាត់បញ្ជាឲ្យគេបាញ់ តាវ៉ែន ហ្នឹងក៏គាត់បញ្ជាឲ្យគេសម្លាប់ចោលដែរ តាវ៉ែន ហ្នឹងនៅនេះ ផ្ទាល់ហ្នឹង កាលហ្នឹងយើងឆ្នាំ៩២-៩៣ហ្នឹងគាត់ខិលខូច ជីកក៏ជីក អីក៏អី ស្រីក៏ស្រីធ្វើបាប គ្រួសារកងទ័ពអញ្ចឹង ដល់ហើយ តាម៉ុក ក៏ដឹងរឿង គេចេះតែប្ដឹងគាត់ទៅ គាត់យកទៅ អន្លង់វែង ។

ប៊ុនថនៈ	គាត់ដក តាវ៉ែន ហ្នឹងទៅអន្លង់វែង?

សែមៈ	គាត់ដកទៅអន្លង់ទៅ ទៅដល់អន្លង់វែងហ្នឹងក៏ប្រព្រឹត្តិរឿងហ្នឹងទៀត ដើរបាញ់ទាបាញ់អីគេ ដើររំលោភប្រពន្ធគេ ដល់ពេលអញ្ចឹងគាត់ទ្រាំមិនបានក៏បញ្ជាឲ្យគេចាក់ថ្នាំឲ្យខ្វិនដើរលែងរួច ដល់ចុងបញ្ចប់ក៏ស្លាប់ទៅ តាវ៉ែន ហ្នឹង នៅសល់តែប្រពន្ធទេ នៅអន្លង់វែងហ្នឹង នៅសល់ កូនសល់អីហ្នឹង ។

ប៊ុនថនៈ	ប៉ុន្ដែ វិន ពូដឹងតែគាត់បញ្ជាឲ្យគេបាញ់?

សែមៈ	ស្លាប់ហើយ ខ្ញុំដឹងព្រោះគាត់និយាយផ្ទាល់ គាត់ថាអញបាញ់ អាវិន ចោលហើយ ។

ប៊ុនថនៈ	តាណា?

សែមៈ	តាម៉ុក ហ្នឹង ។

ប៊ុនថនៈ	អញ្ចឹងគាត់ស្គាល់ពូដែរ?

សែមៈ	ស្គាល់ដែរ គាត់ស្គាល់កាលដែលនៅ ព្រោះគាត់ទៅមកខ្ញុំមកនៅនេះហើយ បានទទួលស្គាល់ ព្រោះគាត់ទៅមកច្រើនចេញចូលជាមួយអ្នកជម្ងឺចុះឡើងអញ្ចឹងណា៎ អញ្ចឹងបានខ្ញុំស្គាល់ គាត់ ហើយគាត់ក៏ស្គាល់ខ្ញុំដែរ ។

ប៊ុនថនៈ	គាត់ស្គាល់ពេលពូរត់ទៅនោះ ឬក៏ស្គាល់តាំងពីមុន?

សែមៈ	ស្គាល់យូដែរហើយ តាំងពី... ។

ប៊ុនថនៈ	តាំងសម័យពាឆ្នាំ?

សែមៈ	បាទ! តាំងពីពាឆ្នាំ ។

ប៊ុនថន: ពូបកទៅក្រោយវិញ ពេលពូចូលទៅខាងស្រុកហ្នឹង ដូចខាងមួយស្រុកហ្នឹងពូមានហាត់អីទេពូ កាលហ្នឹងគេបញ្ជូនពូមកស្រុក?

សែម: កាលហ្នឹងគេហាត់តាំងពីយើងនៅក្នុងភូមិម្ទេះ សមាភូមិហ្នឹង អញ្ចឹងបានខ្ញុំជម្រាបថាសមាជនហ្នឹងគេហាត់ពេលព្រឹកព្រលឹមឡើងហ្នឹង គេដឹកក្របែអញ្ចឹងទៅឲ្យយើងទៅហាត់ហាត់ក្បួនយុទ្ធសាស្រ្ត របៀបថាហាត់លូនហាត់អីអញ្ចឹង តាមស្រែតាមអីទៅ វាមានដែលគេហៅថាអនុប្រធានសន្កាត់ហ្នឹងគេ២០-៣០នាក់អញ្ចឹងគេយកទៅរីករ៉ឹន ឲ្យយើងនេះរៀនលូនរៀនហាត់ រៀនពីរបៀបរបបប្រយុទ្ធអញ្ចឹងណា៎ រៀនពីក្បាច់យុទ្ធសាស្រ្ត ហើយផុតពីហ្នឹងមកគាត់ក៏ដឹងថាយើងរឹងប៉ឹង យើងមាំទាំចេះប្រយុទ្ធចេះអីបានគេបញ្ជូនយើងឲ្យយើងទៅវៃ ទៅសមរភូមិប្រយុទ្ធ ទៅចូលអង្គភាព។

ប៊ុនថន: កាលហ្នឹងនៅម្តុំណា?

សែម: គ្រប់ភូមិទាំងអស់ កាលហ្នឹងឲ្យតែភូមិមួយៗ ឲ្យតែសន្កាត់មួយៗគេរៀបរយអញ្ចឹងហ្នង។

ប៊ុនថន: ប៉ុន្តែពេលបញ្ជូនមកខាងស្រុកហើយ នៅខាងណាវិញទីតាំង?

សែម: ទីតាំងការពិតកាលហ្នឹងគេបញ្ជូនខ្ញុំមកដល់ផ្លាវ ផ្លាវហ្នឹងកន្លែងរៀបចំ ហើយដល់ពេលអង្គភាពដែលជួបជុំគ្នានៅបង្កើត បង្កើតនៅវត្តជើងព្រៃហ្នឹងហ្នង។

ប៊ុនថន: ប្រមូលផ្តុំនៅហ្នឹងហ្នង?

សែម: ប្រមូលផ្តុំនៅហ្នឹង ផុតពីហ្នឹងមកបង្កើតនៅវត្តជើងព្រៃ ហើយដល់ការពិតទ័ពកាលហ្នឹងគេរៀបរយអញ្ចេះ ដល់រដូវប្រាំងបានគេចុះមកសមរភូមិ ដល់រដូវវស្សាបានគេដកទៅវិញណា៎ គេដកគ្រប់ទីតាំងទាំងអស់ ឲ្យនៅតែឈ្លប ឲ្យនៅតែអនាជនប្តអីមួយគ្រាន់ការពារឃ្លាំមើលសកម្មភាពទាហានអញ្ចឹងណា៎ ឯកងទ័ពស្រួចគេដកទៅសម្រាកទាំងអស់ គ្រប់កន្លែងទាំងអស់អត់មាននៅទេ គេដកទៅហាត់រីករ៉ឹនបច្ចេកទេសដូចជា ហាត់លូន ហាត់បោល ហាត់អីៗសព្វបែបយ៉ាង ដល់ពេលរដូវប្រាំងហ្នឹងថ្ងៃមួយខែមួយចាប់ផ្តើមហ្នឹងគឺឡើងទៅសមរភូមិទៅប្រយុទ្ធទាំងអស់គ្នា អង្គភាពណាក៏ត្រូវទៅដែរ សហការណ៍គ្នាទៅវៃហ្នង។

ប៊ុនថន: កាលហ្នឹងពូនៅមុខព្រួញណាវិញ?

សែម: ខ្ញុំនៅខាងជើងភ្នំពេញ។

ប៊ុនថន: ខាងជើងភ្នំពេញ?

សែម: បាទ!

ប៊ុនថន: ពីផ្លូវណាវិញ?

សែមៈ ចាប់ពីព្រែកក្តាម ដល់ក្រោយមកខ្ញុំបានសហការណ៍ជាមួយអង្គភាពខាងចក្រី ចក្រីហ្នឹងគេនៅខាងត្បូងទន្លេ ហើយខ្ញុំនៅខាងជើង ព្រោះក្នុងខេត្តហ្នឹងដែរណា៎ នៅជាប់នឹងខេត្តម៉ាដួរ យើងអាការកោង ម៉ាដួរព្រែកតាមិនព្រែកតាមាក់អីហ្នឹង ផ្លូវហ្នឹង ហើយមួយផ្នែកទៀត ៣១០ហ្នឹងគេតាមដួរផ្លូវព្រែកក្តាម ប៉ុន្តែខាងកើតទន្លេ នៅហ្នឹងមានទន្លេសងខាង ហើយខាងលិចទន្លេមានភូមិភាគគេផ្សេងខាងបច្ចិម គេចែកគ្នាអញ្ចឹង ។

ប៊ុនថនៈ ពូនៅខាងភូមិភាគកណ្តាល?

សែមៈ បាទ! នៅភូមិភាគកណ្តាល ខេត្តកំពង់ចាមភូមិភាគកណ្តាល ។

ប៊ុនថនៈ ខាងត្បូងទន្លេនេះខាងចក្រីខាងបូរ៉ា៏?

សែមៈ ខាងបូរ៉ា៏ គេចែកអញ្ចឹងណា៎ ខាងត្បូងទន្លេតំបន់២១-២២ហ្នឹងខាងបូរ៉ា៏ទេអាហ្នឹង បើនេះទន្លេគឺភូមិភាគកណ្តាលហើយរហូតទៅលើហ្នឹងទៅ ។

ប៊ុនថនៈ ពូនៅជាមួយ សឿន រហូតដល់ដាច់៧៥ហ្មង?

សែមៈ ឈ្មោះ សួង ទេ ។

ប៊ុនថនៈ បាទ! ឈ្មោះ សួង?

សែមៈ នៅទាល់តែដាច់ឆ្នាំ៧៥ដល់៧៦ហ្នឹងបានគេចាប់គាត់ ឆ្នាំ៧៦ហ្នឹងគេចាប់គាត់ទៅ គេថាគាត់ជាយូអា ខ្សែរបស់អាមេរិចអញ្ចឹង ដល់ពេលអញ្ចឹងគេចាប់ហើយ ចាប់ បងសួង ចាប់អី ចាប់តាធុច ចាប់តាយ៉ា ភូមិភាគឧត្តរភូមិភាគអីចាប់ទាំងអស់ មេៗហ្នឹងគេចាប់ទាំងអស់ ។

ប៊ុនថនៈ យ៉ា ហ្នឹងក្រែងគាត់ខាងឥសាន្ត?

សែមៈ បាទ! ខាងឥសាន្តហ្នឹងក៏ចាប់ ចាប់ទាំងអស់ របៀបដូចថាមួយដុំអញ្ចឹងហ្មង មួយខ្សែហ្នឹងគេស្រាវជ្រាវចាប់ទាំងអស់ហ្មង យ៉ា ខាងឥសាន្តហ្នឹងក៏ចាប់ អាហ្នឹងសុទ្ធតែចូលភូមិភាគឧត្តរ ហើយ ហើយ សាន ហ្នឹងគឺភូមិភាគឧត្តរ ភូមិភាគកណ្តាលហើយនឹងភូមិឧត្តរ ។

ប៊ុនថនៈ ឥសាន្តហ្នឹងក្រែងដាច់ភូមិភាគឥសាន្តដាច់តែឯង?

សែមៈ អត់ដាច់តែឯងទេ តែមួយកំណាត់ខាងហ្នឹងគេហៅភូមិឧត្តរ ចុងហ្នឹងទៅជាភូមិភាគឧត្តរ ដូចជាភូមិភាគបច្ចិមហើយនឹងនារតីអញ្ចឹង កណ្តាលនេះខិតមកនេះមកបច្ចិម ដល់ម៉ាដួរខិតទៅបាត់ដំបងអាហ្នឹងគេហៅពាយ័ព្យ ។

ប៊ុនថនៈ អញ្ចឹងពូ សួង កាលហ្នឹងនៅកងពលលេខប៉ុន្មាន?

សែមៈ ៤៥០ ។

ប៊ុនថនៈ ៤៥០?

សែមៈ បាទ!

ប៊ុនថន៖ ហើយលើគាត់មានពីណាទៀត?

សែម៖ លើគាត់អត់មានពីណាទេបើតាមការពិត។

ប៊ុនថន៖ គាត់បញ្ជាការផ្ទាល់?

សែម៖ គាត់ប្រធានកងពល ថ្ងៃដែលចាប់គាត់ហ្នឹងចាប់តាំងពី ចាប់ប្រធានខេត្តមួយដែរ ឈ្មោះតាធុច។ តាធុច ហ្នឹងថាមេក្លោងផងក្នុងភូមិភាគឧត្តរហ្នឹង ក្នុងភូមិភាគកណ្តាលហ្នឹង តាធុចអ្នកខេត្តកំពង់ចាម ហើយនៅសល់គឺនៅសល់កែវ ពក ហ្នឹងទាល់រាល់ថ្ងៃហ្នឹង។

ប៊ុនថន៖ កែវ ពក ឡើងជំនួសក្រោយទេ?

សែម៖ បាទ! អាហ្នឹងដល់៧៨ហើយបានកែវ ពក ឡើងជំនួស។

ប៊ុនថន៖ ហើយកាលមុនគាត់ធ្វើអី?

សែម៖ កែវ ពក អនុរបស់ភូមិភាគកណ្តាល។

ប៊ុនថន៖ អនុលេខា?

សែម៖ បាទ!

ប៊ុនថន៖ ហើយពេលវៃចូលភ្នំពេញហ្នឹង ពូនៅហ្នឹងដែរ ដូចថាខាងណាវៃចូលបានមុន វៃមុនគេ?

សែម៖ ខាងកើតទន្លេគេវៃចូលមុន ខាងចក្រីហ្នឹង។

ប៊ុនថន៖ ខាងចក្រី?

សែម៖ បាទ!

ប៊ុនថន៖ ចុះខាងលិចតាមផ្លូវពោធិ៍ចិនតុង?

សែម៖ ខាងផ្លូវពោធិ៍ចិនតុងអាហ្នឹង៤១០ហ្នឹងក៏គេខិតចូលមកដែរ។

ប៊ុនថន៖ ពីណាគេខ្លះពូកាលហ្នឹង ពូអាចរៀបរាប់បានទេថាកងពលណាខ្លះវៃចូលមក?

សែម៖ កងពល៤៥០ កងពល៣១០ ដូចជាចូលទាំងអស់ ២២១អីហ្នឹង របៀបថាគ្រប់ជ្រុងទាំងអស់គេរួមគ្នាដល់ថ្ងៃដល់ខែគេអញ្ចឹងណា៎ ព្រោះកាលវៃហ្នឹងបើតាមខ្ញុំចាំ មានភ្នាក់ងារនៅក្នុងហ្នឹងស្រេច ម៉ា៎មុខសញ្ញាមួយៗគេចេញមកប្រាប់ដំណឹងថាចូលប្រឡោះនេះប្រឡោះនោះទៅ គេឲ្យចូលទៅអញ្ចឹងបានចូលទៅ ខ្ញុំបាននៅហ្នឹងបានប្រហែលជាកន្លះខែ នៅភ្នំពេញហ្នឹង។

ប៊ុនថន៖ នៅភ្នំពេញ?

សែម៖ ហ្នឹងហើយ គ្រាន់តែវៃហើយខ្ញុំនៅបានកន្លះខែហ្នឹង។

ប៊ុនថន៖ ពូឈរជើងនៅណា?

សែម៖ ដល់ពេលហ្នឹងទៅបានខ្ញុំដកទៅខាងស្ទួល ការពារព្រំដែនស្ទួលហ្នឹង។

ប៊ុនថន៖ វៀតណាមពួចូលឈរជើងនៅណោវិញ?

សែម៖ នៅស្ពានជ្រោយចង្វារ ។

ប៊ុនថន៖ សព្វថ្ងៃនៅម្តុំណាវិញ?

សែម៖ ស្ពានជ្រោយចង្វារនេះ ។

ប៊ុនថន៖ ខាងក្រោមស្ពានហ្នឹងមែនពូ?

សែម៖ ន៎ុ! នៅខាងកើតស្ពាន ។

ប៊ុនថន៖ អញ្ចឹងនៅខាងទន្លេវិញ?

សែម៖ បាទ! មកខាងទន្លេ ហើយកម្លាំងគេពិសេសគេចូលទៅក្នុងទៅ ហើយខាងខ្ញុំគឺនៅ ព្រោះឧទាហរណ៍ថាយើងសាមញ្ញធម្មតាអត់បានចូលទេ គេនៅខាងក្រៅទេ គេនៅតាមត្រង់សេកម្លាំងដែលប្រយុទ្ធហែលទឹកហែលអីទៅ គឺទៅតែអាវុធម៉ាប្រើប្រាស់ម៉ាផ្ទាល់ខ្លួនទេ តែរបស់របរប្រើប្រាស់ដូចជាទូរស័ព្ទ ដូចជាកាំភ្លើង កាំភ្លើងធំ កាំភ្លើងតូចយើងប្រមូលមកដាក់មួយដុំមានកងទ័ពការពារ អត់ឲ្យចូលទាំងអស់ទេ ។

ប៊ុនថន៖ អញ្ចឹងពូទៅឈរជើងនៅស្ពានហ្នឹង?

សែម៖ នៅក្បាលស្ពានខាងកើតហ្នឹង ។

ប៊ុនថន៖ ចុះគេមានរៀបចំបែងចែកអីថ្មីទេ ដល់ពេលជ័យជំនះហើយហ្នឹង?

សែម៖ កាលហ្នឹងគេអប់រំដែរ ប្រធានកងពលអីគាត់មកអប់រំថា ន៎ុ! យើងត្រូវតែប្រយ័ត្ន ត្រៀមដើរល្បាតត្រឹមត្រូវ ព្រោះពួផែនការគេថាអាមេរិចគាំងនឹងវាយបកមកវិញ ។

ប៊ុនថន៖ មានអញ្ចឹងដែរ?

សែម៖ បាទ! គេវាយបកមកវិញ ។

ប៊ុនថន៖ ខាងណា សួង ហ្នឹងអ្នកណែនាំ?

សែម៖ បាទ! គាត់ណែនាំអញ្ចឹង ដល់ពេលចាប់គឺចាប់គាត់ អត់មានដឹងខុសដឹងត្រូវផង គាត់ហ្នឹងអ្នកណែនាំ គាត់ណែនាំឲ្យប្រយ័ត្នប្រយែង យាមស្រួលបួលព្រោះអាមេរិចគាំងនឹងវាយបកយើងវិញ ផែនការរបស់វា កាលហ្នឹងក្រសួងសេអ៊ីអាគេនិយាយអញ្ចឹងណា៎ គេថាសេអ៊ីអាហ្នឹងឲ្យពត៏មានមកយើងស្តាប់បានច្បាស់ហើយ គេនឹងវាយបក គេវាយរបៀបផ្តារីកអញ្ចឹងណា៎ គេវាយយើងពេលដែលយើងចូលទៅក្នុងក្រុងហ្នឹងស៊ុកទៅគេវាយពីក្រៅចូលទៅវិញ គេថាអញ្ចឹងគេរៀបរយអញ្ចឹង ប៉ុន្តែក្រោយមកខ្ញុំសកម្មភាពមានខ្លះដែរ មានផ្ទុះចេញពីអាការកោងពីអីៗមកអញ្ចឹង វាមានផ្ទុះវាយបកអញ្ចឹងណា៎ ប៉ុន្តែដោយកម្លាំងនោះវាអត់មានអីវាមិនធំអីទេ ព្រោះការពិតអាវុធក៏មិនដឹងនៅណាអីនៅណា៎ ។

ប៊ុនថនៈ មានវ៉ៃពីអាការកោងដែរ?

សែមៈ មានចេញវ៉ៃពីអាការកោង ។

ប៊ុនថនៈ មានដឹងថាកម្លាំងខាងណាវ៉ៃទេពូ?

សែមៈ អត់ដឹងខាងណាទេ ប៉ុន្តែគ្រាន់តែទទួលពត៌មានគេប្រាប់ថាខ្មែរស។ វាអញ្ចឹងវិញ វាមានស មានអីណាពេញទឹកពេញដី អាហ្នឹងខ្ញុំមិនច្បាស់ដែរព្រោះគេមិនសូវឲ្យដឹងជ្រៅជ្រះទេ បើគេធ្វើមេធំៗ គេអាចដឹង ។

ប៊ុនថនៈ ចុះមានផ្ទុះឃ្លាំងអាវុធនៅភ្នំពេញពូមានដឹងទេ?

សែមៈ អាហ្នឹងផ្នែកខាងលិច ខាងបច្ចឹមទឹងខាងនារតីអាហ្នឹងផ្ទុះ ប៉ុន្តែផ្ទុះគ្រាប់នៅមកខាងវ៉ៃគ្នានៅម្តុំផ្សារថ្មីផ្សារអីហ្នឹង អាហ្នឹងខ្ញុំនៅខាងកើតទន្លេទេ ខ្ញុំដឹងថាគ្រាប់ផ្ទុះតែគ្រាន់តែសេសសល់ កម្លាំងសេសសល់របៀបថាពួននៅក្នុងលូ ពួននៅក្នុងផ្ទះថ្មយូដល់ពេលហើយវាចេញធ្វើ សកម្មភាពមួយទ្រុលអញ្ចឹង ។

ប៊ុនថនៈ លោកពូនៅបានតែកន្ទះខែទេ?

សែមៈ បាទ! នៅបានកន្ទះខែ ដល់ពេលអញ្ចឹងកាលហ្នឹងដែនការគេថាបក្សឲ្យទៅការពារព្រំដែន ដល់ពេលអញ្ចឹងខ្ញុំទៅមួយវរៈសេនាធំ ទៅព្រំដែនខាងកើត ទៅស្នួល ។

ប៊ុនថនៈ ដកទៅទាំងអស់?

សែមៈ ទៅទាំងអស់ អត់មានសល់អីទេ ។

ប៊ុនថនៈ ពូឈរជើងនៅហ្នឹងរហូតមែនពូ?

សែមៈ បាទ! នៅការពារព្រំដែនហ្នឹងចាប់ពីស្នួលមកក្រចេះ ហើយមកយើងនេះម៉ាជួរខាងកើតមេមត់ហ្នឹង ដើរជួរហ្នឹងរហូត ដើរធ្វើសកម្មភាពការពារព្រំដែន ហើយពេលព្រលឹមឡើងវេចបាយវិចអីទៅហើយ ចេញដើរល្បាតតាមព្រំដែន ។

ប៊ុនថនៈ ពូទៅហ្នឹងរយៈពេលប៉ុន្មាន ទៅស្នួលទៅល្បាត?

សែមៈ ខ្ញុំទៅរយៈពេល២ឆ្នាំ ។

ប៊ុនថនៈ ពីឆ្នាំ..?

សែមៈ ពីឆ្នាំ៧៥-៧៦ ។

ប៊ុនថនៈ ៧៥-៧៦?

សែមៈ បាទ! ដល់ឆ្នាំ៧៦បានដឹងថា បងសួង នេះគេចាប់ហើយ តែខ្ញុំនៅនោះនៅឡើយទេ ព្រោះខ្ញុំទៅតែមួយវរៈសេនាធំទេ អង្គភាពហ្នឹងវា៣វរៈសេនាធំ តែនៅក្រុងហ្នឹងគេ២វរៈសេនាធំ ហើយចេញទៅនោះមួយវរៈសេនាធំ ការពារព្រំដែននៅនោះ ដល់ពេលគេចាប់ បងសួង

ចាប់អីហ្នឹងបានដឹងទទួលថាមេថ្មី តែដល់ពេលហ្នឹងទៅអង្គភាពខ្ញុំហ្នឹងគឺអត់មានទាក់ទិនអីជាមួយពីណាទេ ពីព្រោះដាច់ស្រលះពី បងសួង អញ្ចឹងណា៎ ដល់ពេលអញ្ចឹងទៅបានដាច់ខ្សែស្រឡាយ ដល់ឆ្នាំ៧៧កាលហ្នឹងយួនមិនវ៉ៃនៅនារតី ចាប់ផ្តើមចូលវ៉ៃតាមភ្នំដិន អញ្ចឹងគេដកអង្គភាពខ្ញុំមកទៅជួយវ៉ៃនៅខាងត្បូងតាកែវវិញ ខ្ញុំទៅវ៉ៃនៅហ្នឹងបានមួយឆ្នាំ វ៉ៃនៅតាកែវ ហើយផុតពីហ្នឹងមកបានខ្ញុំទៅឈរជើងនៅខាងកើតមេមត់ ។

ប៊ុនថនៈ ទៅខាងកើតមេមត់វិញ?

សែមៈ បាទ! ទៅខាងមេមត់ ។

ប៊ុនថនៈ ម៉េចបានជាឆ្លាស់គ្នាដូរអញ្ចឹងពូ?

សែមៈ មិនដឹងជាយ៉ាងម៉េច ខ្ញុំមិនយល់ដែរ ឆ្លាស់អាចអញ្ចេះ តាមខ្ញុំដឹងព្រោះពុគេប្រាប់ល្បៀងពុ គេថា អង្គភាពរបស់ ជួន នោះគេហៅតាអឺកង៣៩ ដល់វាទល់ជាមួយជាមួយអង្គភាព ទាល់តែរកអ្នកជើងណាដែលទល់ជាមួយ៣៩ហ្នឹងបាន ទាល់តែដកអង្គភាពនោះទៅទល់គ្នា ដល់ពេលកងទ័ពយួន៣៩ហ្នឹងដកទៅខាងតាកែវក៏យកអង្គភាពខ្ញុំហ្នឹងទៅទល់គ្នានៅហ្នឹង ។

ប៊ុនថនៈ អង្គភាពពូប៉ុន្មាន?

សែមៈ អង្គភាពវរៈសេនាធំហ្នឹង?

ប៊ុនថនៈ បាទ!

សែមៈ កាលហ្នឹងវាដាក់ អា៨៥០ហ្នឹងក្រែងលោ ក្រោយមកគេចាប់ បងសួង ទៅគេកែឈ្មោះដាក់៦០៣វិញ ហើយផុតពីហ្នឹងមកដូចជាភ្លេចលេខអង្គភាព ព្រោះវាច្របូកច្របល់ច្រើនណាស់ខ្ញុំមិនសូវចាំអស់ទេ ព្រោះវាយូពេកហើយ ។

ប៊ុនថនៈ ទល់គ្នាហ្នឹងយ៉ាងម៉េចវិញពូ ដូចថាខាងយួន៣៩ហើយខាងពូអាហ្នឹងគេគិតម៉េចវិញពូ?

សែមៈ មិនដឹងគិតម៉េច ឧទាហរណ៍ថាគេជ្រើសរើសអង្គភាពមួយៗគេថាអ្នកមានថ្វីដៃអញ្ចឹងណា៎ អញ្ចឹងយកទៅទល់ជាមួយកង៣៩របស់វៀតណាមហ្នឹងទាល់តែរើសជើងអ្នកវ៉ៃគ្នាបានទប់ជាប់ បើមិនអញ្ចឹងទេអត់ជាប់ទេ ។

ប៊ុនថនៈ អាហ្នឹងដូចថាគេរើសដូចមេដឹកនាំហ្នឹង?

សែមៈ បាទ! ឧទាហរណ៍ថាដូចមួយវរៈសេនាធំខ្ញុំអញ្ចឹង ពេលឡើងទៅទល់ហ្នឹងគេឲ្យឡើងទៅទាំងអស់ហ្នង ។

ប៊ុនថនៈ គេគិតមួយវរៈហ្នឹងហ្នង?

សែមៈ បាទ!

ប៊ុនថនៈ ដូចថាមួយវរៈហ្នឹងខ្លាំងអញ្ចឹងគេបញ្ជូនទៅ?

សែមៈ បាទ! ទៅដល់ខ្ញុំទៅវៃហ្នឹងទៅ មួយឆ្នាំជាងបានយួនដកចេញពីតាកែវទៅវិញ ពេលហ្នឹងខ្ញុំស្គាល់ តាម៉ុក ពេលហ្នឹង ។

ប៊ុនថនៈ អញ្ចឹងពូទៅហ្នឹង ពូនៅខាងអង្គភាពដដែលឬក៏គេបញ្ជូលទៅខាងហ្នឹង ។

សែមៈ អង្គភាពដដែល នៅមួយវរៈសេនាធំដាច់ដោយឡែកហ្នង អង្គភាពស្រួចហ្នឹងតែមួយវរៈសេនាធំដោយឡែក ។

ប៊ុនថនៈ កាលហ្នឹងពីណាដឹកនាំ?

សែមៈ ហ្នឹងគេផ្លាស់ឈ្មោះហើយ ការពិត តាវិន ហ្នឹង ។

ប៊ុនថនៈ តាវិន កូនប្រសារ តាម៉ុក ហ្នឹង?

សែមៈ បាទ! កូនប្រសារ តាម៉ុក ហ្នឹង ។

ប៊ុនថនៈ គាត់ដឹកនាំតាំងពី គាត់ប្តូរតាំងពីគាត់មកស្នួលហ្នឹងមែនពូ?

សែមៈ គាត់ដូរតាំងពីគេចាប់ បងសួង ហ្នឹងទៅ គេចាប់ បងសួង ទៅឲ្យ បងវិន ហ្នឹងទៅគ្រប់គ្រងដល់ពេលត្រូវការទៅវៃនៅតាកែវ អញ្ចឹងស្រុកកំណើតគាត់នៅតាកែវដកអង្គភាពហ្នឹងទៅគឺទៅនៅតាកែវហ្នឹង ដកពីកើតមកវិញ ។

ប៊ុនថនៈ ទៅទុកទៅហ្នឹង?

សែមៈ បាទ!

ប៊ុនថនៈ អញ្ចឹងពូស្គាល់ តាម៉ុក តាំងពីហ្នឹងមក?

សែមៈ ស្គាល់តាំងពីពេលហ្នឹងមក គាត់សាមញ្ញ មនុស្សគាត់អត់សូវរើសអើងទេ ដើរទៅណាមកណាអត់មានអង្គរក្សមានអីទេ មានតែខោចែវមួយទៅកន្លែងទ័ពកន្លែងអីចេះតែដើរទៅ អត់មានរើសអើងជាមួយអ្នកណាមួយទេ ។

ប៊ុនថនៈ អត់ខ្លាចទេពូ គាត់ទៅម្នាក់ឯង?

សែមៈ ទៅតែឯងៗទេ មិនចាំបាច់មានអង្គរក្សមានអីទេ គាត់ទៅអញ្ចឹងសំណេះសំណាលជាមួយយើង ដាំបាយដាំទឹកទ័ពអីអញ្ចឹងទៅ ជួនកាលគាត់ដើរទៅខ្សែត្រៀមជាមួយយើងអញ្ចឹងទៅដើរសុខទុក្ខធម្មតា គាត់សាមញ្ញអញ្ចឹងបានមនុស្សភាគច្រើនស្គាល់គាត់ អ្នកខ្លះមិនស្រួលហ្នឹងអត់ដឹងថាតាហ្នឹងគណៈភូមិភាគឬអីមួយទេ អត់ដឹងទេ គាត់ច្រើនតែចុះទៅអញ្ចឹងហ្នង បើថានៅសម្រាកពេទ្យសម្រាកអីគាត់ទៅកន្លែងមន្ទីរពេទ្យហ្នឹង ទៅសួរសុខទុក្ខឯងម៉េចអីម៉េចហើយមាត់ឡូវឡាដូចអ្នកដឹកអ្នកអីធម្មតាសាមញ្ញៗអញ្ចឹង ឯងជានៅ ល្អមទៅវិញនៅហើយបើមិនអញ្ចឹងទេដេរពេទ្យដេរអី ដេថាពួកមីអស់នេះឯងមើលប្តីឯងឲ្យឆាប់ជា ឲ្យវាទៅមុខការពារឯងគ្រប់គ្នា ។

ប៊ុនថន: គាត់សាមញ្ញអញ្ចឹងបានអ្នកផ្សេងស្គាល់គាត់ ។

សែម: អញ្ចឹងហើយភាគច្រើនស្គាល់គាត់ ហើយគាត់ក៏ច្រើនតែស្គាល់គេដែរ ដឹងថានៅណាអី សាមញ្ញៗគាត់និយាយអញ្ចឹង ។

ប៊ុនថន: ចុះគាត់អត់មានកាចមានអីទេ?

សែម: តាហ្នឹងតាមមើលអត់ទេ ។

ប៊ុនថន: ដូចថាអ្នកធ្វើខុសធ្វើអី?

សែម: ធ្វើខុសធ្វើហ្នឹងបានត្រឹមវ៉ៃ តែអត់ប្រព្រឹត្តិរឿងអីផ្សេងទេ បានត្រឹមយកត្រពួកដេញវ៉ៃ ឲ្យតែអាណាប្រព្រឹត្តិអីគាត់ដើរទៅកាន់ត្រពួកធម្មតាដូចយើងចាស់ធម្មតា ហើយគាត់ថាឯងម៉េចបានធ្វើអញ្ចឹង ឡើងបេះដូងបេះអីគេកាប់ទាំងស្លឹកទាំងផ្កាយអញ្ចឹង ហើយត្រពួកគាត់វ៉ៃហើយ ។

ប៊ុនថន: ដល់ពេលវ៉ៃហើយគឺហើយ?

សែម: វ៉ៃហើយគឺហើយ អត់មានធ្វើអីទៀតទេ អាហ្នឹងសម្រាប់កងទ័ព ។

ប៊ុនថន: អញ្ចឹងដូចថាអ្នកក្មេងៗ អ្នកពូកែនិយាយអីចូលចិត្តទេ ដូចថាចូលចិត្តរាប់អានអញ្ចឹង?

សែម: បាទ! ដូចថាក្មេងៗអញ្ចឹងគាត់ចូលចិត្ត ហើយគាត់ក៏មិនសូវរើសអើង អ្នកណាប៉ុនព្រោកប៉ុនប្រាជ្ញអី ថ្ងៃៗគាត់ដើរតាមផ្ទះតាមអី អត់មានខ្លាចពីណាពីណីទេ គាត់ទៅធម្មតាៗ មិនសូវរើសអើងឋានៈអីទេ តែខោចែវមួយហ្នឹងទៅហើយ អាវដៃខ្លីខោជ្រវប្រាំគាត់ហ្នឹងអត់មានអ្នកណាដឹងទេ ។

ប៊ុនថន: អញ្ចឹងដូចថាអ្នកអត់ដឹងគាត់ក៏គាត់អត់ប្រកាន់ដែរ?

សែម: អត់ប្រកាន់ទេ តែមើលតែខុសអីដេរស្តីឲ្យ ផុតពីហ្នឹងទៅយើងរត់ចេញ ហើយដូចថាយើងត្រូវការសុំអី ដូចថាសុំនាឡិកា តាសុំនាឡិកាពាក់មួយ អាហ្នឹងគេអ្នកមាត់រអិលដែរសាមញ្ញដូចគ្នា គាត់ថាយកក៏យកទៅអញ្ចឹង យកបានមួយសន្ទុះឯងពាក់ប៉ុណ្ណឹងបានហើយឲ្យទៅអានោះ អានោះវាសុំទៀតហើយ ដល់ហើយឲ្យទៅអានោះទៀតទៅ ។

ប៊ុនថន: អញ្ចឹងគេចូលចិត្តច្រើន ដូចថាគាត់សាមញ្ញ ។

សែម: គាត់សាមញ្ញហើយគេចូលចិត្តគាត់ច្រើន គេស្គាល់គាត់ច្រើន ។

ប៊ុនថន: ហើយលោកពូទៅហ្នឹងមួយឆ្នាំបានផ្លាស់មកឈរជើងនៅស្នួល?

សែម: ទៅស្នួល ដល់ផុតពីហ្នឹងមកខ្ញុំទៅបានប្រហែលជា២ខែរបួសធ្ងន់ ហើយឡើងយន្តហោះមកសម្រាកនៅពេទ្យរហូត ខែ៨ខ្ញុំសម្រាកពេទ្យ ។

ប៊ុនថន: ពូឡើងវ៉ៃដែរបានជារបួស?

សែមៈ កាលហ្នឹងយុទ្ធនាការឃ្លួនគេវ៉ៃធំ តាមម៉ាដួរព្រំដែនឮគ្រប់កន្លែងទាំងអស់ មានកាំភ្លើងតូច កាំភ្លើងធំអីវ៉ៃ ។

ប៊ុនថនៈ ចុះលោកពូកាលហ្នឹងមានដឹង ដូចថាព្រឹត្តិការណ៍បះបោលនៅបូរពាំអីពូមានដឹងទេពូ?

សែមៈ ដឹងដែរ ឮខាងក្រោយគេប្រាប់ ។

ប៊ុនថនៈ កាល៧/៧ហ្នឹងបះបោល?

សែមៈ កាលខ្ញុំទៅដំបូងហ្នឹងដូចការបះបោល ការពិតមិនទាន់ឮការបះបោលទេ ដល់ពេលបះបោលហ្នឹងឮថាខាងក្រោយ តាធុច ហ្នឹងឮការបះបោល គេដកទ័ពគេមួយចំនួន តែអង្គភាពខ្ញុំដូចអត់មានអ្នកណាដកទៅណាទេ គេដកភូមិភាគហ្នឹង គេដកឲ្យទៅរៀបរយទប់ទល់អ្នកបះបោលអញ្ចឹងណ៎ា ។

ប៊ុនថនៈ ដកពីណាវិញពូ?

សែមៈ ដកពីព្រំដែនមកទប់ទល់ កាលហ្នឹងមកទប់ទល់សភាពការណ៍បះបោលអីហ្នឹង តែអង្គភាពខ្ញុំអត់មានដកទៅណាទេ កាលបះបោលហ្នឹងខ្ញុំនៅនារតីទេ ។

ប៊ុនថនៈ ពូនៅនារតីទេ?

សែមៈ បាទ! ខ្ញុំនៅតាកែវ អត់ទាន់ទៅហ្នឹងវិញផង ប៉ុន្តែគ្រាន់តែគេប្រាប់ដំណឹង គេប្រាប់ថានៅភូមិភាគបូរពាំហ្នឹងក្បត់ហើយ តាធុច ទាំងយាយការ៉ូ យាយអីហ្នឹង ហើយខ្ញុំនៅជាប់ព្រំដែនខាងត្បូងនេះអត់ទាន់ទៅហ្នឹងវិញទេ ដល់ពេលគេរៀបរយអីហ្នឹងហើយស្រួលបួលបានខ្ញុំដកអង្គភាពខ្ញុំទៅនោះវិញ ដកបានប៉ុន្មានទេ ប្រហែលជា២ខែខ្ញុំរបួសធ្ងន់ ។

ប៊ុនថនៈ អញ្ចឹងពូស្គាល់ ធុច ច្បាស់ដែរ គាត់នៅកំពង់ចាមដែរ?

សែមៈ ការពិតស្រុកកំណើតគាត់នៅខាងត្បូងភូមិទេ ស្គាល់មិនសូវច្បាស់ទេ បើកែវ ពក បានខ្ញុំស្គាល់ច្បាស់ ។

ប៊ុនថនៈ កែវ ពក ដូចនៅកំពង់ចាមដែរពូ?

សែមៈ នៅកំពង់ចាមដែរហ្នឹង កែវ ពក បងអឿន អីហ្នឹងបងប្អូនគាត់ ការពិតស្រុកកំណើតគាត់នៅព្រៃឈរ ។

ប៊ុនថនៈ ឈ្មោះអី អឿន?

សែមៈ ឈ្មោះ អឿន ប្អូនថ្លៃគាត់ ។

ប៊ុនថនៈ ស្អីអឿន?

សែមៈ មិនដឹងអីទេ ភ្លេចហើយព្រោះវាយូឆ្នាំដែរហើយ ។

ប៊ុនថនៈ គាត់កាន់ខាងអីដែរ?

សែមៈ កាលហ្នឹងមិនដឹងធ្វើការងារអីទេ បើកែវ ពក បានទទួលភូមិភាគ អាចគណៈតំបន់តាមមើល អឿន ហ្នឹងតែពូគេប្រាប់តែកាលហ្នឹងខ្ញុំនៅព្រំដែន ខ្ញុំមិនស្រាវជ្រាវ អត់ដឹងឈ្មោះខាងក្រោយហ្នឹងយ៉ាងម៉េចអីយ៉ាងម៉េចអត់ដឹងទេ ។

ប៊ុនថនៈ គណៈតំបន់ណាពូ?

សែមៈ ភូមិភាគកណ្តាលហ្នឹងគេហៅតំបន់ តំបន់អីទេចង់ភ្លេចហើយ ដូចជាតំបន់មួយម្តុំព្រៃឈរអីហ្នឹង ខ្ញុំអត់ចាំដែរវាភ្លេចទៅណា៎ ។

ប៊ុនថនៈ ពូអត់សួរច្បាស់ទេ?

សែមៈ បាទ! ខ្ញុំភ្លេចហើយ រឿងវាវែងឆ្ងាយត្រលប់ត្រឡិនបាយបិនជាបាយបាត ខ្ញុំវាអត់ចាំអស់ទេ ហើយក៏មិនបានសរសេរទុក ទោះបីសរសេរក៏វាមិននៅដែរព្រោះសភាពការពិបាកណាស់ មកទល់សព្វថ្ងៃនេះឆ្ងកាត់សព្វបែបសព្វយ៉ាង ។

ប៊ុនថនៈ ហើយចុះ អឿន ហ្នឹងគាត់នៅរស់ទេ ដល់ក្រោយមកឆ្នាំ៧៩?

សែមៈ តាមមើលដូចនៅ បើសិនជានៅអាចនៅអន្លុងវែង ។

ប៊ុនថនៈ សព្វថ្ងៃ?

សែមៈ បាទ! នៅជាមួយកែវ ពក បងថ្លៃប្អូនថ្លៃគេ ។

ប៊ុនថនៈ គាត់ភូមិភាគកណ្តាល?

សែមៈ បាទ! គាត់អាចនៅទៀតព្រោះតាមដំណឹងពូថានៅ កែវ ពក ក៏នៅដែរ នៅទាំងអស់ តែផ្លូវមិនដឹងយ៉ាងម៉េច ។

ប៊ុនថនៈ ចុះអោម អួន ពូស្គាល់ទេ?

សែមៈ អត់ទេ ។

ប៊ុនថនៈ អោម អួន ដូចជាភូមិភាគកណ្តាលដែរពូ?

សែមៈ ខ្ញុំអត់ច្បាស់ដែរ ក្រែងលោខ្ញុំចេញផុតព្រោះគេនៅក្រោយ ខ្ញុំអត់សួរច្បាស់ដែរ ព្រោះមកនៅទ័ព តែចេញមកទ័ពអត់បានដឹងទេរឿងក្រោយ សូម្បីតែឪពុកម្តាយខ្លួនឯងក៏អត់មានដឹងដែរ មានដឹងសុខដឹងទុក្ខអីយ៉ាងម៉េចផង ហើយម៉ែខ្ញុំនឹងខ្ញុំជាអ្នករងគ្រោះមួយដែរការពិតផ្លូវរស់នៅតែ៣នាក់បងប្អូន ឪពុកម្តាយ ប្អូនស្រីៗគេសម្លាប់ចោលទាំងអស់ ដល់ពេលទៅលេងទៅអី ផ្លូវមកនៅទន្លេនៅកងហ្នឹង ព្រោះស្រុកម្តាយខ្ញុំនៅកងហ្នឹង ហើយឪពុកខ្ញុំនៅស្គន់ ដល់ពេលអញ្ចឹងទៅស្រាវជ្រាវរកបង រកម៉ែរកឪទៅ ឆ្នាំ៧៦យើងធ្វើសាមារណកម្ម ដល់ពេលទៅដល់បាត់ម៉ែបាត់ឪអស់អាលឹង សល់តែ៣នាក់បងប្អូន នៅប្អូនពៅខ្ញុំមួយ ហើយបងបង្អួសមួយ ហើយនៅតែខ្ញុំមួយទេ នៅប្រុសៗ៣នាក់ហ្នឹងហើយក្រៅពីហ្នឹងស្លាប់

ទាំងអស់ ឪពុកម្ដាយអីស្លាប់ទាំងអស់ ស្លាប់នៅសម័យហ្នឹង ប៉ុន្តែមិនដឹងគេសម្លាប់នៅណា អីណាទេខ្ញុំមិនបានស្រាវជ្រាវរកឲ្យអស់ តែភាគច្រើនគេថាសម្លាប់នៅភ្នំស្រីភ្នំប្រុស កំពង់ចាម ហើយខ្លះគេសម្លាប់នៅស្គន់ ប្អូនប្រុសៗខ្ញុំស្លាប់ទាំងអស់ អញ្ចឹងបានជាខ្ញុំខ្ជិល លែងចង់ទៅស្រុកទៅអី ខ្ញុំនៅតែហ្នឹងខ្ញុំលែងទៅណាហើយ ទៅម្ដងៗខ្ញុំតូចចិត្តនឹងខ្លួនឯង តូចចិត្តរឿងស្រុកភូមិដល់ហើយខ្ជិលទៅអើត ។

ប៊ុនថន៖ អញ្ចឹងលោកពូដកទៅហ្នឹង ត្រូវរបួសត្រង់ណា?

សែម៖ ត្រូវទាំងជើង ត្រូវទាំងខ្នង ខ្នងហ្នឹងត្រូវកាត់អាច្រឡូកហ្នឹង ហើយខ្ញុំមកសម្រាកពេទ្យប្រហែល៦-៧ខែ គ្រាន់តែសន្លប់៣ខែបានខ្ញុំដឹងខ្លួន មានគេតានុសផង ហើយស្រីៗខ្ញុំហ្នឹងគេអ្នកនៅពេទ្យគេអ្នកមើល ហើយពេលរត់មកហ្នឹងជួបគ្នារហូតទៅ ដល់ពេលក្រោយមកក៏ជិតស្និទ្ធគ្នាទៅហើយក៏ទំនាក់ទំនងគ្នាបានគ្នាទៅទាល់រាល់ថ្ងៃហ្នឹង អត់មានឪពុកម្ដាយណារៀបចំទេ សម្រេចចិត្តដោយខ្លួនឯង ។

ប៊ុនថន៖ អញ្ចឹងលោកពូនៅហ្នឹងស្គាល់ យាយការ៉ូ ដែរទេ?

សែម៖ បាទ! កាលហ្នឹងស្គាល់ ហើយការពិតក៏គាត់មានលក្ខណៈសាមញ្ញដូច តាម៉ុក ដែរយាយហ្នឹងហើយសោ ភឹម ហ្នឹងក៏អញ្ចឹងដែរ ការពិតគាត់ក៏មានលក្ខណៈសាមញ្ញដូច តាម៉ុក ដែរ គាត់ប្រធានភូមិភាគ ទៅណាមកណាគាត់មិនសូវនេះទេ ការពិតគាត់មិនសូវរើសអើងជាមួយទ័ពទេ មានអីអត់អីហ្នឹង ។

ប៊ុនថន៖ ប៉ុន្តែកាលហ្នឹងពូនៅផ្សេងគ្នាទេ ដូចសោ ភឹម គាត់នៅខាងបូព៌ាហើយពូនៅខាងឧត្ដរ?

សែម៖ បាទ! នៅផ្សេងគ្នា ប៉ុន្តែគ្រាន់ថាលក្ខណៈសាមញ្ញ ខាងទន្លេម្ខាងម្នាក់ទៅវិញទៅមកអត់អីទេស្គាល់គ្នា ហើយចាន់ ចក្រីហ្នឹងក៏ស្គាល់ដែរ ។

ប៊ុនថន៖ ចាន់ ចក្រីហ្នឹងគាត់អ្នកស្រុកណាដែរ?

សែម៖ គាត់អ្នកស្រុកហ្នឹងដែរ ដូចជានៅម្ដុំព្រៃសន្ធរអីហ្នឹង ។

ប៊ុនថន៖ ស្រុកកំណើតគាត់?

សែម៖ បាទ! ស្រុកកំណើតគាត់ នៅម្ដុំៗអស់ហ្នឹងតាមមើល នៅជិតៗហ្នឹង ប៉ុន្តែគាត់មនុស្សអំណាចហើយរាងហំណាស់ ចក្រី ហ្នឹង ហើយគាំភ្លើងមិនដែលសៀតមួយដើមទេ សៀតសុទ្ធតែ២ដើម ដូចយើងមើលកុនចិនអញ្ចឹងណា៎ គាត់អំណាចហើយបានរោហា និយាយអីគេច្រើនតែស្ដាប់ ការពិតគាត់ប្រធានកងពលធំ អញ្ចឹងអំណាចហើយព្រោះគេជ្រើសរើសមនុស្សមេទ័ពខាងថ្មើរជើង ដល់ពេលអញ្ចឹងគេចាប់ទាំងគាត់ ចាប់ទាំងតាសួងអស់អាលីង ។

ប៊ុនថន៖ ចាប់មួយវគ្គជាមួយគ្នាហ្នឹងមែន?

សែមៈ បាទ! ចាប់មួយវគ្គជាមួយគ្នាហ្នឹងអស់ច្រើនណាស់ មេៗកងពលខាងថ្មើរជើងហ្នឹងទៅទាំងអស់ ទាំងវរៈសេនាធំទាំងអីយកទៅទាំងអស់តែមិនដឹងយកទៅដាក់នៅណាទេ ប៉ុន្តែការពិតតាមស្តាប់ទៅដាក់នៅទួលស្លែងហ្នឹងទាំងអស់ យកទៅដាក់គុកទួលស្លែង ចាប់ពេលនោះបើតាមដឹងខ្ញុំយល់ថាចាប់តាមខ្សែហ្នឹង អត់មានចាប់ថាអ្នកណាប្រព្រឹត្តិខុសឬត្រូវអីអត់ទេ បើតាមខ្ញុំដឹងតាមខ្សែហ្នឹង ឧទាហរណ៍ខ្សែ បងស្ងួន អញ្ចឹងអ្នកណាដែល បងស្ងួន បញ្ចូលជាបក្សហើយគឺចាប់យកទាំងអស់ឲ្យតែចូលបក្ស បើនៅប្រព័ន្ធយូកកយូអីហ្នឹងគេហៅថានេះហ្នឹងគឺអត់ទេ អត់មានទាក់ទិនទេ ឲ្យតែខ្សែបក្សហ្នឹងគឺចាប់ហ្នឹង ។

ប៊ុនថនៈ ចាប់ពីថ្នាក់ណាដល់ថ្នាក់ណាពូ បើតាមពូដឹង?

សែមៈ ឲ្យតែបញ្ចូលបក្ស ជួនកាល... ។

ប៊ុនថនៈ ឋានៈតួនាទី?

សែមៈ ឋានៈតួនាទីបញ្ចូលទៅជាបក្សហ្នឹងគឺមេខ្លួចគេចាប់ទាំងអស់ហ្នឹង ។

ប៊ុនថនៈ បក្សជនហ្នឹងមែនពូ?

សែមៈ បាទ! បក្សជនហ្នឹងបើតាមខ្ញុំយល់ អញ្ចឹងបានជាពិបាក ។

ប៊ុនថនៈ ប៉ុន្តែដូច សោ ភឹម ដូចថាមានពូនៅជិតអញ្ចឹង ពូអាចដឹងដូចថាគាត់មានរៀបចំផែនការណ៍បះបោលអញ្ចឹងមែន ឬក៏ម៉េចបានជាគេចាប់?

សែមៈ បញ្ហាហ្នឹងពុតែគេផ្សព្វផ្សាយ ហើយខ្ញុំដូចជាមិនសូវជឿប៉ុន្មានទេ ដូចគេថាផ្សព្វផ្សាយថាគាត់រៀបចំផែនការណ៍បះបោលអីអញ្ចឹងណា៎ ប៉ុន្តែនៅក្នុងហ្នឹងការរៀបចំបះបោលអីបើកងទ័ពគាត់នៅព្រំដែនទាំងអស់ដដែល ហើយភស្តុតាងច្បាស់បើតាមខ្ញុំគិត ហែក ហួរ ដណ្តើមអំណាចគ្នា របៀបដណ្តើមអំណាច ឧទាហរណ៍ថានៅភូមិភាគនារតីអញ្ចឹងទៅអញ្ចចង់ធ្វើនេះធ្វើនោះ អញ្ចឹងដណ្តើមអំណាចដើម្បីធ្វើបានទាល់តែសង្កត់ថាមនុស្សហ្នឹងកើតជាស្អីៗអញ្ចឹងទៅ អាហ្នឹងបើតាមខ្ញុំយល់ណា៎ ព្រោះកាលពេលហ្នឹង សុន សេន គាត់ត្រូវទៅឈរជើងនៅស្លួងយើងហ្នឹង ព្រោះអគ្គសេនាធិការហើយគាត់កាលហ្នឹង គាត់ទៅឈរជើងនៅហ្នឹងហើយម៉េចបានទៅ ខ្ញុំយល់ថាអាចគេញោះញ៉ុងដណ្តើមបុណ្យស័ក្តគ្នាតាមមើល ព្រោះកន្លែងមកដូច តាវ៉ែន តាអីមកលិចនេះហើយ កាលហ្នឹងយើងបង្កើតត្រីភាគីនេះហើយ តាវ៉ែននេះក៏ដណ្តើមបុណ្យស័ក្តដែរ ។

ប៊ុនថនៈ ដណ្តើមយ៉ាងម៉េចវិញ?

សែមៈ ដណ្តើម ឧទាហរណ៍ថាគេអំណាចគេទទួលមួយកំណាត់ពីត្រឹមម៉ានៗ ថ្នាក់បីកងពលអញ្ចឹងទៅតាវ៉ែន ហ្នឹងដណ្តើមអំណាចគេ ។

ប៊ុនថនៈ គាត់ទៅក្តាបយក?

សែមៈ បាទ! គាត់ទៅក្តាបយក ហើយទៅចោទគេថាអ្នកហ្នឹងខុស អ្នកហ្នឹងអីអញ្ចេះអញ្ចុះអញ្ចឹង ។

ប៊ុនថនៈ កាលហ្នឹងគាត់ចោទពីណាខ្លះពូ?

សែមៈ កាលហ្នឹងចោទ តែអត់ទៅរួច កាលហ្នឹងចោទ តាបិត ។

ប៊ុនថនៈ សំ បិត ហ្នឹង?

សែមៈ បាទ! សំ បិត ការពិត តារ៉ែន ចោទដែរហ្នឹង ហើយចោទបងជីដូនមួយស្រីៗខ្ញុំនេះ កាលហ្នឹងគាត់រត់បាក់បែកគ្នាទៅ អញ្ចឹងទៅស្រុកថៃ ដល់ពេលទៅដល់ស្រុកថៃហ្នឹងថៃគេពាក់ស័ក្ក ៥ឡូ តែដល់ពេលដឹងរឿងអញ្ចឹងខាងលើ តានួន គាត់ដឹងអញ្ចឹងគេទៅប្រមូលឡប់មកវិញ ប្រមូលឲ្យមកនៅខ្មែរយើងវិញ ដល់ពេលអញ្ចឹង តារ៉ែន ចោទសម្លាប់គាត់អី ថាគាត់ហ្នឹងអញ្ចេះអញ្ចុះ បើតាមខ្ញុំដឹងរឿងហ្នឹងគឺរឿងមុខមាត់ដណ្តើមគ្នា ព្រោះតាមខ្ញុំយល់គេថារបៀបមនុស្សល្ងង់ ហើយដល់ពេលអញ្ចឹងគេចេះចោទទៅ ឧទាហរណ៍ថាគេអំណាចធំជាងដល់ពេលអញ្ចឹងថាគេខុស ហើយចេះតែចោទគេ រឿងហ្នឹងគឺរឿង ហែក ហួរ បើតាមខ្ញុំដឹង ។

ប៊ុនថនៈ បងប្អូនខាងគ្រួសារពូហ្នឹងគាត់ឈ្មោះអី?

សែមៈ ចង់ភ្លេចឈ្មោះហើយ កាលហ្នឹង តារ៉ែន ប្រហែលជា តារ៉ែន ហ្នឹងសម្លាប់ ហើយខ្ញុំស៊ើបសួរទៅគេសម្លាប់គាត់ចោល ឲ្យអង្គរក្សសម្លាប់ហ្នឹងបានគាត់ស្លាប់ហ្នឹង ។

ប៊ុនថនៈ ពូដឹងដែរ?

សែមៈ ដឹង ត្បិតតែខ្ញុំនៅផ្ទះមែន តែខ្ញុំខឹង តារ៉ែន ដល់សព្វថ្ងៃហ្នឹង អាហ្នឹងបើតាមខ្ញុំយល់គឺល្បិចអញ្ចឹងឯង ។

ប៊ុនថនៈ ដល់ពេលអញ្ចឹងថ្នាក់លើគេអត់ថាអីដែរ តាៗ?

សែមៈ ថ្នាក់លើ?

ប៊ុនថនៈ បាទ! ដូចតាៗធ្វើអីអត់កើតទេ?

សែមៈ ថ្នាក់លើរបៀបដូចតុលាការ ហើយដូច តានួន អីដូចតុលាការ តែគ្រាន់តែមកដល់ តារ៉ែន វាគបាត់ហើយ អញ្ចឹងធ្វើប្រព្រឹត្តសកម្មភាពអីមុនហ្នឹង តានួន ទៅដល់ហ្នឹង តារ៉ែន ទៅគៀកបាត់ ហើយកាលនោះបើតាមខ្ញុំយល់ មេៗអស់ហ្នឹងបើតាមខ្ញុំដឹង តាមខ្ញុំសង្កេតមើលសកម្មភាពពេលគាត់ទៅណាមកណាអត់ឲ្យមានជួបអ្នកណាទេ មានអង្គរក្សដើរពីមុខហ្នឹងប្រាប់ថា នែ៎ក! ចូលព្រៃសិនទៅ អ៊ីគាត់មកហើយ ហើយអញ្ចឹងយើងជាទ័ព ជាប្រជាពលរដ្ឋអីចូលព្រៃទៅឲ្យគាត់ដើរចូលតែគាត់ ហើយគេអ្នកការពារតាមផ្លូវអញ្ចឹងណា៎គេអត់ឲ្យជួប

ហ្នឹង របៀបថាពន្ធនាងអ្នកដឹកនាំហ្នឹងហើយនឹងប្រជាពលរដ្ឋហ្នឹងអត់ឲ្យជួបគ្នាហ្នឹង មិនឲ្យមានពាក្យសន្ទនាប្ងនិយាយអីទេ ហើយចាស់ៗហ្នឹងឲ្យតែជួបគាត់ចេះតែសួរសុខទុក្ខនិយាយពីនេះពីនោះហើយ ប៉ុន្តែដល់ពេលអញ្ចឹងមិនឲ្យមានជួបហ្នឹង មិនឲ្យមានពត៌មានហ្នឹងពីក្រោមឡើងមកលើ មានតែពីលើចុះមកក្រោម តាមខ្ញុំមើលពេលគាត់ត្រូវចេញទៅណាមកណាអីហ្នឹងមានអង្គរក្សគេដើរមុនហ្នឹងជួបយើងហ្នឹងប្រាប់ចូលព្រៃសិនទៅ អឹមកហើយ អត់ឲ្យជួបទេៗ

ប៊ុនថន: ខាង តាវ៉ែន ហ្នឹង?

សែម: បាទ!

ប៊ុនថន: ប៉ុន្តែមិនមែនដូចថាគាត់មានឥទ្ធិពលដូចថាគាត់ជាកូនប្រសារ តាម៉ុក ទេ?

សែម: អាហ្នឹងហើយ វាមានឥទ្ធិពលពីគាត់ហ្នឹងហើយ ដល់ពេលអញ្ចឹងធ្វើទៅគេជឿហ្នឹង ដល់ពេលអញ្ចឹង តាឡូន មកហ្នឹងទៅគៀក តាឡូន ទៅ តាឡូន ជឿហ្នឹងថាអ៊ំ! អាហ្នឹងកូនប្រសារតាម៉ុក អីអញ្ចឹងណា៎ ព្រោះកាលហ្នឹង តាម៉ុក គេមិនតែតាំងជាអគ្គសេនាធិការ ដល់ពេលអញ្ចឹងគេជឿហ្នឹង អញ្ចឹងអត់មានរកភស្តុតាងអីបានទេ អត់មានអ្នកណាហ៊ានមាត់ហ៊ានអីទេមិនអញ្ចឹងទេគេរករឿងៗ

ប៊ុនថន: ម៉ាដំនៀរនេះខាង តាឡូន អ្នកមើល?

សែម: ម៉ាដំនៀរនេះ?

ប៊ុនថន: បាទ! ហើយ តាប៉ុល អីដែលចុះមកទេ?

សែម: កាលដើមឡើយគាត់នៅហ្នឹង នៅហ្នឹង ច«១»យើងនេះ កាលគាត់ចុះគឺចុះនៅខាងជើងនោះទេ ដល់ពេលច្រកគ្រប់កន្លែងកាលហ្នឹងដែនការណ៍ យួនគេវ៉ៃបើកយុទ្ធនាការវ៉ៃព្រំដែនហ្នឹងគឺនៅសល់តែមួយច្រកហ្នឹងទេ នេះគេហៅថាភ្នំក្រវាញហ្នឹងគឺមិនផាយចូលដល់ដែរ គឺងតែងណាស់ ហើយភាគច្រើនអង្គរក្សរបស់គាត់គឺសុទ្ធតែជនជាតិៗ

ប៊ុនថន: អង្គរក្សរបស់ តាប៉ុល មែន?

សែម: បាទ! អង្គរក្សរបស់គាត់ភាគច្រើនសុទ្ធតែជនជាតិ មានពួកព្នង ពួកអីហ្នឹងយកមកការពារពួកតាកែន ពួកតាទូអីហ្នឹងសុទ្ធតែជនជាតិទាំងអស់ៗ

ប៊ុនថន: ពូមានស្គាល់គាត់មួយឈ្មោះ តាជៀម គាត់អង្គរក្សដែរ គាត់នារសាផ្ទាល់ គាត់នៅម៉ាឡៃឈ្មោះ នង ជៀម គាត់ខាង..ឥឡូវក្រុមប្រឹក្សានៅម៉ាឡៃ?

សែម: ជៀម?

ប៊ុនថន: បាទ! គាត់ជនជាតិដែរ?

សែម: អញ្ចឹង?

ប៊ុនថនៈ បាទ! ឥឡូវគាត់នៅរស់តើលោកពូ គាត់ក៏ជនជាតិដែរ?

សែមៈ អត់អីទេការពិត រាល់ថ្ងៃគាត់នៅពួកតាទូ ពួកតាកេងពួកអីហ្នឹងសុទ្ធតែជនជាតិទាំងអស់ ហើយពួក តាឡាំង តាកែន ហ្នឹងកាលនៅភ្នំពេញឋានៈ៨៧០ ការពិត តាឌុច នេះក្រុម តាកែន នេះទេ តាកែន ហ្នឹងប្រធានធំណា៎ គណៈ៨៧០គ្រប់គ្រងម៉ាក្រុងភ្នំពេញណា៎ ប្រធានក្រុងណា៎ ។

ប៊ុនថនៈ តាកែន?

សែមៈ បាទ!

ប៊ុនថនៈ ឈ្មោះអីកែន?

សែមៈ មិនដឹងស្អីកែនទេ តែឥឡូវស្លាប់ហើយ គ្រាន់ថាគាត់ស្លាប់ទៅស្វាត់ស្បៀម កាលហ្នឹងគាត់ ទាចប្តថ្មើមក្រិនទេស្លាប់បាត់ទៅ គាត់ស្លាប់នៅច«១»នេះ ។

ប៊ុនថនៈ គេហៅ៨៧០ហ្នឹង?

សែមៈ បាទ! គណៈ៨៧០ ។

ប៊ុនថនៈ គេហៅមជ្ឈឹម?

សែមៈ បាទ! គ្រប់គ្រងក្នុងមន្ទីរហ្នងអាហ្នឹង គ្រប់គ្រងលើ តាឌុច តាអីទៀត គណៈ៨៧០ហ្នឹងមានន័យថាមួយក្រុងហ្នឹងគាត់ទទួលទាំងអស់ ។

ប៊ុនថនៈ ហើយចុះ ឌឿន ពូមានដែលស្គាល់ទេ?

សែមៈ ឌឿន?

ប៊ុនថនៈ បាទ! ឌឿន ហ្នឹងគាត់ខាងមន្ទីរ៨៧០ដែរ?

សែមៈ ឌឿន ណាអញ្ចេះ?

ប៊ុនថនៈ តែគាត់ប្រហែលជាចាប់ខ្លួន?

សែមៈ អញ្ចឹង?

ប៊ុនថនៈ បាទ! ឌឿន ហើយនីង ឈឹម សំអោក ហៅប៉ង់?

សែមៈ ជួនកាលគេប្រែឈ្មោះ កាលពេលហ្នឹងគេដាក់ឈ្មោះផ្សេង តែឥឡូវគេប្រែផ្សេងអញ្ចឹង ណា៎ ។

ប៊ុនថនៈ ប៉ុន្តែពូនិយាយម៉េញហ្នឹងគាត់ឡើងក្រោយទៀតមែនទេពូ តាដែលថាស្លាប់ហ្នឹង?

សែមៈ អត់ទេ ការពិតយូហើយ តាំងពីឆ្នាំ៧៥មក ។

ប៊ុនថនៈ គាត់ឡើង?

សែមៈ ៧៥ ហ្នឹងការពិតគណៈ៨៧០គឺ តាកែន ហ្នឹងហ្មង តែគ្រាន់តែគេហៅជាកិច្ចការស្ងាត់ណា៎ នៅក្នុងហ្នឹងគ្រប់គ្រងទាំងអស់ ទាំងតាឌុច តាអីហ្នឹង ម៉ាក្រុងហ្នឹងហ្មង មិនមែន តាឌុច នេះទេ តាឌុច ហ្នឹងការពិតគាត់គ្រប់គ្រងខាងគុក ។

ប៊ុនថនៈ ខាងសន្តិសុខ?

សែមៈ អត់ទេ ខាងនគរបាល ការពិតគាត់ផ្នែកខាងគុកហ្នឹងហ្មង ហើយតាកែន ហ្នឹងបានគាត់គ្រប់គ្រងជារួមហ្មង អង្គរក្សនៅជុំវិញក្រុងប៉ុន្មាន មនុស្សនៅគណៈ៨៧០ហ្នឹងគឺរួមទាំងអស់ហ្មង គាត់ប្រធានធំជាង ឌុច ហ្នឹងទៀត តាកែន ហ្នឹងជនជាតិតែឥឡូវហ្នឹងគាត់ស្លាប់ហើយ ហើយប្រពន្ធមិនដឹងនៅណាអីណីទេ ។

ប៊ុនថនៈ ឈ្មោះ កែន ហ្មង?

សែមៈ បាទ! ឈ្មោះ កែន ។

ប៊ុនថនៈ ហើយមានឈ្មោះហៅក្រៅទៀតទេ?

សែមៈ អត់មានឈ្មោះហៅក្រៅទេ គេហៅតាកែន អញ្ចឹងហ្មង ។

ប៊ុនថនៈ គាត់នៅគណៈ៨៧០ហ្នឹងរហូត?

សែមៈ បាទ! តែភាសាខាងក្រៅហ្នឹងគេហៅគណៈ៨៧០ គ្រាន់តែពូឈ្មោះហ្នឹងគេដឹងហ្មង តាំងពីនារសាក្រុងអីៗហ្នឹងនៅក្រោមការគ្រប់គ្រងរបស់គាត់ទាំងអស់ ។

ប៊ុនថនៈ គាត់ជនជាតិអីពូ?

សែមៈ ដូចជាគួយ តាកែន ហ្នឹងដូចជាគួយ ក្បាលរាងធំបន្តិច ស្មាទោសចុះដូចជាក្បាលស្វាអញ្ចឹង ។

ប៊ុនថនៈ ប៉ុន្តែគាត់អត់សូវចេញឈ្មោះទេ?

សែមៈ អត់សូវចេញឈ្មោះទេ បើគេហៅគឺហៅតែគណៈ៨៧០អញ្ចឹងហ្មង គណៈ៨៧០អត់មានឈ្មោះទេ តែមកដល់នេះបានគេ....។

ប៊ុនថនៈ ពូដឹងក្រោយទេ កាលពីមុនអត់ដឹងទេ?

សែមៈ ពីមុនអត់ដឹងគណៈ៨៧០ពីណាទេ ដល់ក្រោយមកបានដឹងថាអ៎ តាកែន ហ្នឹងគណៈ៨៧០ ។

ប៊ុនថនៈ ដឹងហ្នឹងគាត់និយាយផ្ទាល់ ឬក៏?

សែមៈ គាត់និយាយ គាត់មិននិយាយទេ តែភាគច្រើនអ្នកនៅជុំវិញដូច តាស៊ីម ដូចអីៗដែលនៅជុំវិញហ្នឹងគាត់និយាយប្រាប់ថាគាត់ហ្នឹងគណៈ៨៧០ ។

ប៊ុនថនៈ ស៊ីម ណាពូ?

សែមៈ ស៊ីម ហ្នឹងឥលូវមិនដឹងជានៅណាទេ ដូចជានៅលង្វែង ។

ប៊ុនថន៖ គាត់ធ្វើអីវិញពូ?

សែម៖ ស៊ីម ហ្នឹងដូចជាអន្តរក្សប៉ុល ពត ដែរ នៅជុំវិញមន្ទីរដែរហ្នឹង ហើយស៊ីម ហ្នឹងគាត់ដូចជាជនជាតិគួយដែរ រាល់ថ្ងៃប្រហែលជានៅលង្វែក ។

ប៊ុនថន៖ អញ្ចឹងតាហ្នឹងគាត់គ្រប់គ្រងតាំងពីហ្នឹង ប៉ុន្តែអត់ដែលព្ញុឈ្មោះទេ?

សែម៖ បាទ! អត់ដែលព្ញអ្នកណាថាស្គាល់គាត់គឺជាស្អី តែដល់ពេលមកនៅជុំគ្នាបានដឹងថាគាត់ជាគណៈ៨៧០ ។

ប៊ុនថន៖ ប៉ុន្តែកាលចេញមកហើយហ្នឹងគាត់តួនាទីអីទៀត?

សែម៖ ការពិតគាត់នៅគ្រប់គ្រងជុំវិញតាប៉ុល ពត ហ្នឹង នៅរៀបរយកម្លាំងការពាររបស់គាត់ជុំវិញ ហើយរៀបរយកម្លាំងដឹកជញ្ជូនកម្លាំងអី គ្រប់គ្រងឃ្លាំងស្បៀងគ្រប់បែបយ៉ាង ។

ប៊ុនថន៖ ពេលបែកចេញហើយហ្នឹង?

សែម៖ បាទ! ក្រោយពីមកពីភ្នំពេញហើយមកជុំគ្នានៅនេះវិញ កាលហ្នឹងយើងរៀបចំត្រីភាគី តាំងរណបុទ្ធិ តាំងអីៗហ្នឹងបូកចូលគ្នា ហើយអតីតខ្មែរក្រហមហ្នឹងគេមានតាំងពីឃ្លាំងដឹកស្បៀងដឹកអីធម្មតាវិញ ។

ប៊ុនថន៖ អញ្ចឹងពូទើបតែដឹងក្រោយនេះទេ?

សែម៖ បាទ! ខ្ញុំទើបតែស្គាល់ឈ្មោះ កាលនៅភ្នំពេញខ្ញុំអត់មានស្គាល់គណៈ៨៧០ច្បាស់លាស់ទេ តែដល់ពេលមកនេះមកបានដឹងថា តាកែន ជាគណៈ៨៧០ ហើយបានស្គាល់ពួក តាស៊ីម ពួនអីនៅជុំវិញ ហើយសុទ្ធតែជាជនជាតិ ។

ប៊ុនថន៖ ចុះពូ ត្រលប់ទៅក្រោយវិញដូច តាភឹម ហើយនឹងយាយ ការ៉ូ អីហ្នឹងដូច តាម៉ុក ដែរ ដូចថាគាត់មានប្រជាប្រិយ?

សែម៖ បាទ! គាត់មានប្រជាប្រិយ លក្ខណៈសាមញ្ញ គាត់ទៅណាមកណាអីអត់មានរើសអើងពណ៌សម្បុរមនុស្សទេ មិនដឹងជាយ៉ាងម៉េចបានទៅជាគាត់គេចោទថាគាត់ហ្នឹងក្បត់ កាលហ្នឹងថាក្បត់ជាមួយគណៈភូមិភាគ ។

ប៊ុនថន៖ ពាយ័ព្យ?

សែម៖ បាទ! ពាយ័ព្យ ។

ប៊ុនថន៖ អាហ្នឹង តាញឹម?

សែម៖ បាទ! រស់ ញឹម ។ រស់ ញឹម ហើយនឹងសោ ភឹម ហ្នឹងគេថាគាត់ដណ្តងហ្នឹងគ្នា ។

ប៊ុនថន៖ បាទ! កូននឹងកូន គាត់ជាដណ្តងហ្នឹងគ្នា ។

សែមៈ តែខ្ញុំមិនបានស្គាល់ទេ បើស្គាល់គឺស្គាល់តែ សោ ភឹមទេ សោ ភឹម ហើយនឹងយាយ ការ៉ូ គាត់ទៅណាមកមានឡានមានអី គាត់ទៅដើរៗ គាត់សាមញ្ញ គាត់ទៅសួរសុខទុក្ខទ័ពសួរអី ហ្នឹង អាហ្នឹងបានខ្ញុំស្គាល់ ។

ប៊ុនថនៈ គាត់មានកូនប៉ុន្មាននាក់ សោ ភឹម ហ្នឹង?

សែមៈ មិនដឹងកូនប៉ុន្មាននាក់ទេ ខ្ញុំមិនច្បាស់ទេរឿងកូន ព្រោះគាត់អត់សូវនៅជាប់នឹងខ្លួនទេ តែមានកូនមានអីហ្នឹងសុទ្ធតែមានគេបម្រើចិញ្ចឹមផ្សេងហើយ អត់មាននៅជាមួយគាត់ទេកូនគាត់ ព្រោះគាត់អ្នកនេះដែរ ការពិតគាត់ទ័ពដែរ ទ័ពទាំងប្ដីទាំងប្រពន្ធ ដាក់ឈ្មោះយាយការ៉ូ ដោយសារគាត់បាញ់អាការ៉ូយន្តហោះធ្លាក់ហ្នឹងបានដាក់ឈ្មោះគាត់ហ្នឹង យាយការ៉ូ ។

ប៊ុនថនៈ អ៎! បាញ់ធ្លាក់កាលជំនាន់សង្គ្រាម៥ឆ្នាំហ្នឹង?

សែមៈ បាទ! កាលជំនាន់៥ឆ្នាំហ្នឹង អាការ៉ូក្រឡោកដូងហ្នឹងហោះដើរឆែកហ្នឹងគាត់បាញ់ធ្លាក់ទៅបានដាក់ឈ្មោះគាត់យាយការ៉ូៗទៅ ។

ប៊ុនថនៈ អញ្ចឹងគាត់ខ្លាំងដែរ?

សែមៈ បាទ! អញ្ចឹងបានគាត់ក្លាយទៅជាកងទ័ព អត់សូវមានកូននៅជាប់ទេ ខ្ញុំអត់ស្គាល់ច្បាស់ទេកូនគាត់ បើស្គាល់គឺស្គាល់តែគាត់ហ្នឹង ។

ប៊ុនថនៈ គាត់តួនាទីអីដែរ យាយការ៉ូហ្នឹង?

សែមៈ យាយហ្នឹងដូចជាវរៈសេនាតូច ។

ប៊ុនថនៈ ប្រធានវរៈសេនាតូច?

សែមៈ បាទ! ប្រធានវរៈសេនាតូច ដល់ក្រោយមកមិនដឹងគាត់ជាប់ខាងអីៗ ព្រោះខ្ញុំដាច់រយៈពីគាត់មក ខ្ញុំអត់ច្បាស់ដែរហ្នឹង ។

ប៊ុនថនៈ វរៈសេនាតូចលេខប៉ុន្មានពូមាននៅចាំទេ?

សែមៈ អត់ចាំទេ ច្របូកច្របល់គ្នា ប៉ុន្តែភាគច្រើនគាត់នៅតំបន់២១ ខ្ញុំដឹងតែគាត់នៅតំបន់២១ ហ្នឹង ។

ប៊ុនថនៈ ២១ហ្នឹងខេត្តអីខ្លះពូ អ៎! មានស្រុកអីខ្លះពូ?

សែមៈ អត់ចាំអស់ទេ ដូចជាម្ដុំមេមត់ហ្នឹង ២១ហ្នឹងរាប់តាំងម្ដុំនែមានអីទៅ អាខាងត្បូងស្ទឹងហ្នឹងម្ដុំសួង ម្ដុំក្រែកម្ដុំអីហ្នឹង តំបន់២១ដូចជាទៅកើតទៀត ម្ដុំមេមត់ ខាងនេះស្នួលមកអាហ្នឹងគេហៅតំបន់២១ទាំងអស់ហ្នឹង ដូចជាក្រចេះដែរបូកចូលហ្នឹង អាហ្នឹងសុទ្ធតែតំបន់២១ហើយ ។

ប៊ុនថនៈ អញ្ចឹងខាងហ្នឹងគាត់?

សែមៈ បាទ!

ប៊ុនថនៈ ហើយពូមានព្រឹត្តិការណ៍ថាក្រោយពី សោ ភឹម ចាប់អីហ្នឹងមានដូចថាប្រែប្រួលអីទេ នៅខាងហ្នឹង ខាងបូព៌ាហ្នឹង?

សែមៈ ខ្ញុំអត់ច្បាស់ទេ ព្រោះកាលហ្នឹងកាលដែលគេដេញចាប់គាត់ខ្ញុំនៅតាកែវ អត់ដឹងថាយ៉ាងម៉េចទេ ដល់ពេលរៀបរយ ហើយយួនវៃខ្លាំងនៅម៉ាដូរមេម៉ត់ហ្នឹងបានដកពួកខ្ញុំទៅនៅស្នួល ។

ប៊ុនថនៈ ចុះកាលដកហ្នឹងដូច ហេង សំរិន អីគាត់ទៅខាងបូព៌ាដែរកាលហ្នឹង?

សែមៈ តាហេង សំរិន គាត់នៅមេម៉ត់ហ្នឹង ស្រុកកំណើតគាត់នៅមេម៉ត់ហ្នឹង ។

ប៊ុនថនៈ ប៉ុន្តែគាត់ដូចកងពលដែរ?

សែមៈ អត់ទេ ការពិតគាត់អនុរក្សរបស់ តានួន នារសារបស់ តានួន ។

ប៊ុនថនៈ នួន ជា ហ្នឹងមែន?

សែមៈ បាទ!

ប៊ុនថនៈ អ៊ុំ! គាត់នារសា?

សែមៈ បាទ! ដល់ក្រោយមកបានឲ្យគាត់គ្រប់គ្រងវរៈសេនាតូចនៅប្រចាំតំបន់ហ្នឹង ។

ប៊ុនថនៈ វរៈសេនាតូច?

សែមៈ បាទ!

ប៊ុនថនៈ កាលហ្នឹងគាត់អនុរក្សតាំងពីសម័យតស៊ូ?

សែមៈ អាចតាំងពីសម័យមក តាំងពី៧០ពីអីមក ខ្ញុំមិនបានច្បាស់ទេ តាហេង សំរិន ហ្នឹងព្រោះកន្លែង តានួន ហ្នឹងមិនសូវហ៊ានមានអ្នកណាចេញចូលបានទេ ។

ប៊ុនថនៈ កាលហ្នឹងគាត់នៅណាវិញពូ តានួន?

សែមៈ តានួន ហ្នឹងមិនដឹងជាកន្លែងណាឲ្យច្បាស់លាស់ទេ ដូចជានៅភ្នំពេញដែរកាលរំដោះហើយតែគ្រាន់តែក្រោយមកមិនដឹងនៅកន្លែងណាឲ្យច្បាស់លាស់ទេ ។

ប៊ុនថនៈ ពេលសម័យតស៊ូហ្នឹងគាត់នៅកំពង់ចាម នៅស្ទឹងត្រង់នៅអីដែរហ្នឹង?

សែមៈ កាលហ្នឹងគាត់នៅខាងត្បូងមេម៉ត់ នៅភូមិការៀននៅអីហ្នឹង ម៉ាដូរហ្នឹង តែខ្ញុំមិនដឹងទេព្រោះគេប្រាប់ខ្ញុំដែរ ។

ប៊ុនថនៈ គាត់ប្រាប់ពូមែន?

សែមៈ បាទ! គាត់ប្រាប់ ។

ប៊ុនថនៈ ពូធ្លាប់ជួបគាត់ដែរ?

សែមៈ ធ្លាប់ តាំងពីហ្នឹងមក ចុះកងទ័ពយើងនៅជិតៗគ្នាហ្នឹង កាលហ្នឹងយើងមិនមែននៅឆ្ងាយពីគ្នាអី ព្រោះអង្គភាពខាងភូមិភាគកណ្ដាលការពិតថ្មើដើងទាំងអស់ អញ្ចឹងតែងតែជួបគ្នាដែរ ដល់ពេលគាត់ទៅនៅអង្គរក្សជាមួយ តាទួន ទៅក្រោយមកក៏បែកគ្នាទៅ បែកគ្នាអាចបែក៧៨ហ្នឹងឯងបើតាមមើលសភាពការណ៍ខាងហ្នឹង ហើយខ្ញុំទៅខាងតាកែវទៅ អាចគាត់រត់ចូលវៀតណាម អាចប្រហែលជាអញ្ចឹង ។

ប៊ុនថនៈ ប៉ុន្តែពូដឹងកាលមុនហ្នឹងជានារសារបស់ តាទួន?

សែមៈ បាទ! នារសារបស់ តាទួន ។

ប៊ុនថនៈ គាត់ឡើងជាវរៈសេនាតូចឆ្នាំប៉ុន្មាន?

សែមៈ កាលហ្នឹងឲ្យទៅគ្រប់គ្រងហ្នឹង ដូចពូថាឲ្យធ្វើវរៈសេនាតូច វរៈសេនាតូចតំបន់២១ ហើយដល់ក្រោយមកមិនដឹងជាយ៉ាងម៉េចទៀត ព្រោះខ្ញុំនៅតាកែវ ដល់ពេលខ្ញុំដកទៅស្អួល...

ប៊ុនថនៈ បាត់គាត់?

សែមៈ បាទ! បាត់គាត់ទៅលែងបានជួបគ្នាហើយ ។

ប៊ុនថនៈ ប៉ុន្តែដែលពូដំណឹងគាត់ទេ?

សែមៈ ពូដំណឹងថាគាត់រត់ដែរ ។

ប៊ុនថនៈ រត់ដែរ?

សែមៈ រត់ទៅវៀតណាម ។

ប៊ុនថនៈ អញ្ចឹងមួយវរៈសេនាតូចគាត់ទៅទាំងអស់មែន ឬក៏នៅខ្លះ?

សែមៈ អាចទៅទាំងអស់មួយវរៈសេនាតូចគាត់ ព្រោះនៅហ្នឹងជិតដែរ ព្រំប្រទល់មុំជាអីហ្នឹង ហើយដូចជាមិនដល់មួយគីឡូពីថ្នល់ផង ព្រំដែនហ្នឹងវាជិតដែរ សុទ្ធតែព្រៃកៅស៊ូមួយជួរហ្នឹង ព្រោះសភាពការណ៍កាលគេចាប់ សោ ភឹម ហ្នឹងរឿងហ្នឹងហើយបានជាគាត់ទៅហ្នឹង អាចរឿងហ្នឹងព្រោះខ្ញុំជាប់នៅតាកែវ ។

ប៊ុនថនៈ គាត់នារសា តាទួន តាំងពីឆ្នាំណាទៅ លោកពូមានដឹងទេ?

សែមៈ នែ៎! ខ្ញុំមិនច្បាស់ទេ ដឹងតែនារសារបស់ តាទួន ហើយ តាទួន ហ្នឹងក៏ខ្ញុំអត់ច្បាស់ដែរ មិនដឹងស្រុកកំណើតគាត់នៅណាដែរ ។

ប៊ុនថនៈ គាត់នៅបាត់ដំបង ។

សែមៈ នៅបាត់ដំបង?

ប៊ុនថនៈ បាទ!

សែម៖ អញ្ចឹងបើអាចជាប់មកនៅភ្នំពេញហ្នឹងហើយតាមមើលបានអាចទៅជាអក្ខរក្សរបស់ តានួន ហើយ តានួន ហ្នឹងក៏ខ្ញុំអត់ស្គាល់ច្បាស់ដែរ ហើយប៉ុល ពត ក៏ខ្ញុំអត់ដែលស្គាល់ដែរ បើតាសុន សេន បានខ្ញុំស្គាល់ ស្គាល់កាល៧៧-៧៨ហើយបានខ្ញុំស្គាល់ ។

ប៊ុនថន៖ គាត់ដកទៅខាងព្រំដែន ។

សែម៖ ទៅខាងមេម៉ត់ហ្នឹង នៅម៉ាជួរ គេហៅស្នួង គាត់ដាក់ទីតាំងនៅហ្នឹង កាលហ្នឹងបានអាសារជួប ។

ប៊ុនថន៖ គាត់ទៅយូរទេពូ កាលទៅព្រំដែន?

សែម៖ ទៅហ្នឹងអាចប្រហែលជាមួយឆ្នាំ មុំស្នួងហ្នឹង ព្រោះគេបែកមេចុះ អគ្គសេនាធិការហ្នឹងគឺចុះទៅហ្នឹង ។

ប៊ុនថន៖ ពីណាខ្លះ តាសុន សេន?

សែម៖ មានតែតា សុន សេន ហ្នឹងមួយទេ ក្រៅពីហ្នឹងដូចអត់ឃើញមានអ្នកណាទៅ?

ប៊ុនថន៖ គាត់ទៅហ្នឹងគាត់ក្តោបក្តាប់រួមបុក៏យ៉ាងម៉េច?

សែម៖ បញ្ជូទីតាំងនៅហ្នឹងហ្នង បញ្ជូរបៀបបញ្ជាកងទ័ព អគ្គសេនាធិការឃើញមានតែគាត់ទេ ប៉ុន្តែកន្លែងគាត់ហ្នឹងភាគច្រើនមិនសូវបានចូលដែរហ្នឹង ព្រោះភាគច្រើនសុទ្ធតែជនជាតិក្មេងៗគាត់បង្រៀនឲ្យនិយាយភាសាខ្មែរយើង យកជនជាតិមកច្រើនមកបង្រៀន រាប់រយនាក់ ហើយពួកហ្នឹងមិនងាយឲ្យយើងចូលទេ យើងសុំវាអីនិយាយខ្មែរអត់ច្បាស់ផងហ្នឹង សុទ្ធតែក្មេងជំទង់ៗកាលខ្ញុំទៅ នៅហ្នឹងអត់ឲ្យចូលទេ កន្លែងហ្នឹងតឹងតែងណាស់មិនងាយឲ្យចូលផ្តេសផ្តាសទេ ។

ប៊ុនថន៖ អញ្ចឹង រិន ដែលពូនៅហ្នឹងនៅកន្លែងហ្នឹងដែរ គាត់ឈរជើងនៅហ្នឹងដែរ?

សែម៖ កាលមុនគេនៅតាកែវទេ ។

ប៊ុនថន៖ ប៉ុន្តែពូដកពីតាកែវទៅហ្នឹង?

សែម៖ ដល់ពេលដកពីតាកែវទៅ ទៅគ្រប់គ្រងនៅកងពលហ្នឹងហ្នង ។

ប៊ុនថន៖ គាត់នៅហ្នឹងដែរ?

សែម៖ នៅហ្នឹងដែរ ដល់ពេលឲ្យវរៈសេនាធំរបស់ខ្ញុំទៅកើតទៅ តារិន ទៅហ្នឹងដែរ គេដកទៅនៅហ្នឹងដែរនៅមេម៉ត់ហ្នឹង តែអង្គភាពខ្ញុំនៅខាងកើតនោះទេ មុំស្នួល ។

ប៊ុនថន៖ ហើយសុន សេន គាត់នៅស្នួង?

សែម៖ បាទ! សុន សេន ហ្នឹងនៅស្នួងយើងជិតផ្លូវជាតិហ្នឹង ខាងនេះដាបន្តិចមក ព្រុងណើងថាអគ្គសេនាធិការគេនៅហ្នឹង ។

ប៊ុនថន:	ហើយចុះដូច សម្ដេចហ៊ុន សែន អីពូមានស្គាល់គាត់ដែរ កាលនោះគាត់នៅខាង?

សែម:	អត់មានបានជួបទេគាត់នៅខាងកើត វរៈសេនាតូចហ្នឹងតាមមើលខុសគ្នាពីតា ហេង សំរិន វរៈសេនាតូចហ្នឹងអាចនៅចុងខាងកើត ។

ប៊ុនថន:	គាត់វរៈសេនាតូចដែរ?

សែម:	បាទ! វរៈសេនាតូចដែរហ្នឹង ។

ប៊ុនថន:	ប៉ុន្មាន តំបន់២១មែន?

សែម:	មិនដឹងប៉ុន្មានទេគាត់ហ្នឹង ព្រោះខ្ញុំអត់ច្បាស់ដែរ ព្រោះចុងដែរ អាហ្នឹងតាមមើលកាលហ្នឹងដូចគេរៀបបីវរៈសេនាតូចកងទ័ពហ្នឹង ហ្នឹងហើយអាចបីវរៈសេនាតូច កងទ័ពហ្នឹងមិនមែនកងទ័ពភាគទេ ដែលគេហៅទ័ពតំបន់គេ ។

ប៊ុនថន:	តំបន់?

សែម:	បាទ! តំបន់ ។

ប៊ុនថន:	អញ្ចឹងគាត់មិនមែនភាគទេ ខាងតំបន់?

សែម:	ពីណាគេ?

ប៊ុនថន:	សម្ដេច?

សែម:	សម្ដេចគាត់នៅតំបន់ទេ ។

ប៊ុនថន:	មិនមែនភាគទេ?

សែម:	បាទ! មិនមែនឡើងដល់កងទ័ពភាគទេ សម្ដេចកាលហ្នឹងគាត់នៅកងទ័ពតំបន់ទេ ដូចជានៅតំបន់២១ដែរជាមួយលោកតា ហេង សំរិន ដែរ ប៉ុន្តែអាចបីវរៈសេនាតូចហ្នឹងតាមមើលអាចគ្រប់គ្រងរបស់សោ ភឹម ហ្នឹងឯងតាមមើល អត់មានប្រធានកងពលទេ រឿងហ្នឹងអាចអញ្ចឹង ព្រោះខ្ញុំការពិតខ្ញុំកងទ័ពស្រួចទេខ្ញុំអត់ក្តាប់អត់បានទេ ព្រោះតំបន់ទ័ពអីខ្ញុំអត់បានចូលជ្រៅទេ ។

ប៊ុនថន:	អញ្ចឹងដាច់ពីគ្នាមែនពូ?

សែម:	បាទ! ដាច់ ព្រោះការពិតកងទ័ពស្រួចគេរៀបចំតែ១២កងពលទេ អាហ្នឹងបើតាមខ្ញុំដឹងមាន៤៥០ មាន៤១០ ហើយមានអីទៀតទេដូចជាភ្លេចអស់ហើយ ហើយមាន២២០របស់ តាសារឿន ហ្នឹង ហើយអគ្គភាពរបស់ចក្រីនេះ១២១-១២២ ៥០២នេះកងពលធំ ៥០២នេះតាមពិតការងារដីនៅបច្ចុមហ្នឹងគេរៀបម៉ាកងពល៥០២ហ្នឹងទាំងថ្មើរជើងទាំងរថក្រោះ ទាំងកាំភ្លើងធំទាំងអស់ អាហ្នឹងគេចែកគ្នា ។

ប៊ុនថន:	អញ្ចឹងកងទ័ពពូស្រួចហ្នឹងដាច់ដោយឡែកផ្សេង?

សែមៈ ដាច់ដោយឡែក ការពិតបញ្ជារបស់អគ្គសេនាធិការអត់មានចូលជាមួយភូមិភាគអីបញ្ជាបាន អីទេ របស់អគ្គសេនាធិការបញ្ជាផ្ទាល់ហ្នឹង ដកទៅណាមកណាអីអត់មាន ។

ប៊ុនថនៈ អញ្ចឹងពូនៅក្រោមអគ្គសេនាធិការទៀត?

សែមៈ បាទ!

ប៊ុនថនៈ កាលនោះសុន សេន មែនគាត់ក្តោប?

សែមៈ បាទ! សុន សេន គាត់អគ្គសេនាធិការ មេបញ្ជាកងទ័ពទូទាំងប្រទេស ។

ប៊ុនថនៈ ចុះលោកពូត្រូវរបួសហ្នឹងវៃខ្លាំង កាលហ្នឹងវៃខ្លាំងហ្នឹង?

សែមៈ វៃខ្លាំង វៃទាំងយប់ទាំងថ្ងៃ ដូចជាវៃតែថ្ងៃទេ របួសចូលទៅដល់ព្រៃហ្នឹង ឲ្យតែយប់គឺនាំគ្នា សម្រាកទាំងអស់គ្នា ដូចយើងសន្យាគ្នាអញ្ចឹងណា៎ ទាំងវៀតណាមក៏អញ្ចឹងដែរ ដល់ពេលគឺ មើលអីលែងឃើញទាំងអស់នៅក្នុងព្រៃ ថ្ងៃវៃគ្នាគ្រាន់តែបើកភ្នែកឡើងព្រលឹមឡើងគ្រាន់ តែភ្លឺច្បាស់វៃគ្នាហ្នឹង ទាំងកាំភ្លើងតូចទាំងកាំភ្លើងធំ ទាំងរថក្រោះពេញទឹកពេញដីហើរពេញ មេឃទាំងអស់ ហើយដល់ពេលយប់ស្ងាត់ជ្រាបហ្នឹង នាំគ្នាសម្រាកទាំងអស់ អត់មានដើរ រួចទេ ។

ប៊ុនថនៈ ហើយនេះច្រើនទេ ដូចថាវៃចូលខាងវៀតណាមអី?

សែមៈ ដំបូងឡើយយើងវៃចូលទៅមែន ដល់ពេលក្រោយមកយើងមិនអាចវៃចូលទៅបានទេ បើ យើងប្រៀបធៀបកងទ័ពវៀតណាមវា២៨កងពល ហើយយើងមានតែ១២កងពលទេ បើ យើងប្រៀបធៀបថ្មើរជើង អានេះយើងបូកចូលគ្នាទាំងអស់ អញ្ចឹងកងទ័ពវៀតណាមកាល ហ្នឹងគេលើកមកវា២៨កងពល វាមកសន្ធ្រប់មនុស្សតែប៉ុន្មានកងពលហ្នឹងទេ ហើយយើងក៏ មិនអាចទប់បានដែរ ព្រោះមនុស្សច្រើនណាស់ ឃើញទេមកហូរ ចេះតែមកច្រើនឡើងៗ ។

ប៊ុនថនៈ ឆ្នាំប៉ុន្មានពូត្រូវរបួស?

សែមៈ ខ្ញុំតាំងពី៧៨មកត្រូវរបួស ។

ប៊ុនថនៈ ៧៨ដើមមែន?

សែមៈ បាទ! ៧៨ដើម ។

ប៊ុនថនៈ ត្រូវរបួសច្រើនទេកាលហ្នឹង?

សែមៈ ត្រូវក្បាលជង្គង់ ត្រូវដៃ ត្រូវខ្នង ត្រូវសព្វតាំងពីពោះតាំងពីលែងដឹងខ្លួន ដើរបីខែគិតមើល ខែ១ អាស៎តាំងពីខែ៧ ចុងខែ៧ ខែ៨ ខែ៩ ខែ១០ ខែ១១ ខែ១ អាហ្នឹងវៀតណាម ចូលមក ប៉ុន្មានខែហ្នឹងខ្ញុំដើរអត់រួចផង ដល់ពេលគេបណ្តើរបានដើររួច គេដឹករទេះភ្លើងតាម ស្រីៗខ្ញុំគេធ្វើពេទ្យហ្នឹងមកចុះបាត់ដំបងហ្នឹង ហើយមានដែលបានទៅវិញអី ។

ប៊ុនថន: អញ្ចឹងពូនៅពេទ្យហ្នឹងទាល់តែបែកហ្នង?

សែម: អត់ទេ ខ្ញុំអត់នៅពេទ្យទេខ្ញុំនៅកងទ័ព ហើយកាលហ្នឹងខ្ញុំរបួសគេចាត់ទុកជាអ្នកជម្ងឺអញ្ចឹងណា៎ នៅរួមជាមួយពេទ្យទៅ ពេលនេះពេទ្យគេចាក់ថ្នាំឲ្យទៅ គេព្យាបាលឲ្យទៅ ប៉ុន្តែយើងដើររួច ហើយអ្នកដើរអត់រួចហ្នឹងនៅលើរទេះភ្លើងហ្នឹងទៅ ស្លាប់ទាំងអស់ យើងដើររួចរំកិលរួចចេះ តែទៅតាមពេទ្យ យើងដើររួចអត់អីទេ ចេះតែទៅតាមពេទ្យទៅ រត់តាមពេទ្យអញ្ចឹងទៅ ហើយបានទៅជួប តាម៉ុក ជួបអីអញ្ចឹងទៅគាត់រៀបរយឲ្យនៅកន្លែងមន្ទីរកន្លែងអីក្រោយ ទៅ យើងអត់មានទៅវ៉ៃអីកើតទេ យើងនៅមន្ទីរគាត់ ចាំផ្ទះចាំកន្លែងឲ្យគេទៅ ។

ប៊ុនថន: កាលហ្នឹងនៅណាវិញពូ?

សែម: ខ្ញុំនៅព្រំដែន ពេលមកដល់នេះនៅព្រំដែន ។

ប៊ុនថន: ព្រំដែនណាវិញ?

សែម: នៅសំឡូតដែរហ្នឹង ។

ប៊ុនថន: នៅខាងសំឡូត?

សែម: បាទ! នៅម៉ាជួរអាណោងយើងហ្នឹង ។

ប៊ុនថន: ប៉ុន្តែពូមកដល់ហ្នឹងរាងគ្រាន់បើទេ ដូចថារាងធូរជាងមុនទេ?

សែម: រាងធូរជាងមុន ។

ប៊ុនថន: អាចដើរបានទេ?

សែម: អាចដើរបានអីបាន ហើយនៅចាំកន្លែងឲ្យគេ ដល់ពេលផុតពីហ្នឹងមកតាំងពីឆ្នាំ៨០-៨១-៨២-៨៣-៨៤រហូតខ្ញុំនៅមន្ទីររហូត តែគ្រាន់បានជួយរៀបរយគេ ពេលគេទៅមុខទៅក្រោយអីហ្នឹង យើងគ្រាន់ចាំមន្ទីរចាំកន្លែងឲ្យគេអញ្ចឹងទៅ ពេលគេទៅណាទៅណីអីយើងមើលចាំកន្លែង អត់មានវ៉ៃអីកើតទៀតទេព្រោះខ្លួនទៅជាពិការហើយ ។

ប៊ុនថន: នៅខាងមន្ទីរ?

សែម: បាទ!

ប៊ុនថន: នៅមន្ទីរជាមួយ តាម៉ុក ហ្នង?

សែម: អត់ទេ នៅជាមួយ តាឌួន តាឌួន ហ្នឹងកងពលដែរហ្នឹង ។

ប៊ុនថន: ស្អី ឌួន?

សែម: ស្អី ឌួន ទេ តាឌួន យាយ តន ឥឡូវអាចស័ក្ត៥ ឌួន ហ្នឹងនៅបាត់ដំបងដែរ ស្អី ឌួន ទេ អត់ចាំត្រកូលទេ ចាំតែឈ្មោះ កូនតាចាយតើតាឌួន ហ្នឹង តាឌួន ហ្នឹងតាម៉ុក រៀបការឲ្យដែរហ្នឹង ។

ប៊ុនថន: ការជាមួយពីណាពូកាលហ្នឹង?

សែម: ការជាមួយ តាចាយ យាយតន ហ្នឹង ការកាលហ្នឹង៧៧ ។

ប៊ុនថន: កាលហ្នឹងគាត់ធ្វើអី?

សែម: គាត់វរៈសេនាធំ ។

ប៊ុនថន: វរៈសេនាធំ ប៉ុន្តែកាន់ខាងភូមិភាគណា?

សែម: កាលហ្នឹងនៅជាមួយ តាម៉ុក ។

ប៊ុនថន: តែនៅភូមិភាគនារតី?

សែម: បាទ! ភូមិភាគនារតី តែដល់ក្រោយមកគាត់មកចូលកាន់កាប់កងពលជាមួយ តាវិន ដែរ ។

ប៊ុនថន: ៥១០ហ្នឹងមែន?

សែម: ដូចជា៦០៣ទេ ។

ប៊ុនថន: ៦០៣?

សែម: បាទ!

ប៊ុនថន: អញ្ចឹងនៅពូនៅមន្ទីរហ្នឹងនៅជាមួយគាត់ហ្នឹង?

សែម: បាទ! នៅជាមួយគាត់រហូតមកទល់៨០ ។

ប៊ុនថន: ប៉ុន្តែកាលហ្នឹងគេបែកចែកមុខសញ្ញាណាខ្លះពូ ដូចថាគ្រប់គ្រងខាងម៉ាឡៃ ខាងប៉ៃលិន ហើយខាងភ្នំព្រឹកខាងអីអញ្ចឹង គេបែងចែកយ៉ាងម៉េចពូ?

សែម: អាហ្នឹងអង្គភាពគេផ្សេង ឧទាហរណ៍ថានៅប៉ៃលិនខាងអ៊ី ឈានអញ្ចឹងទៅ មកសំឡូតខាងបងម៉េត ព្រោះគេឈរមួយកន្លែងៗ ច្រកគេអញ្ចឹងណា៎ ហើយមកនេះមានពីណា តាប៉ុលពតនៅនេះហ្នង ហើយតានួន តាប៉ុល ពត អញ្ចឹងក្រោមបញ្ជាពេលប្រជុំពេលអីពេលគាត់រៀនសូត្ររៀនអីហ្នឹង សាលាគេនៅត្រាតទល់រាល់ថ្ងៃហ្នឹង ហៅប្រមូលពីហ្នឹងមកថៃដឹកតាមព្រំដែនមកបើកសាលារៀនទៅ ។

ប៊ុនថន: មេៗតាៗហ្នឹងមែន?

សែម: បាទ! តាៗហ្នឹងនៅជិតត្រាត ជិតបង្គោលអគ្គីសនីថៃ គេហៅស្អីទេខ្ញុំអត់ស្គាល់ដែរ ។

ប៊ុនថន: អញ្ចឹងដំបូង តាប៉ុល ហ្នឹងមកនេះទេ គាត់មកសំឡូតនេះទេ?

សែម: គាត់តាមមើលចុះនៅខាងជើង តែតានួន ចុះនៅយើងនេះ ចុះយើងនៅពាមតានេះ អាហ្នឹងតានួន ហើយប៉ុល ពត អាចចុះនៅខាងជើងនោះ ចុះទៅដីថៃណា៎ ប៉ុន្តែដល់ពេលមកនៅគឺមកនៅនេះ មកនៅមូលគ្នា ។

ប៊ុនថន: មូលគ្នានៅណា?

សែមៈ នៅច«១»យើងរាល់ថ្ងៃនេះ ដល់ពេលនៅច«១»សភាពការណ៍អត់ល្អចុះទៅនៅត្រាតដីថៃ ជួលដីគេនៅ ជួលដីថៃនៅ។

ប៊ុនថនៈ ហើយ តាម៉ុក គាត់មកនេះវិញ?

សែមៈ ដល់ក្រោយមក តាម៉ុក អត់នៅហ្នឹងវិញ តាម៉ុក ទៅខាងជើងវិញ។

ប៊ុនថនៈ ទៅខាងលង្វែង?

សែមៈ បាទ! ទៅលង្វែងវិញ។

ប៊ុនថនៈ ម៉េចបានជាគាត់ដូរទៅហ្នឹងវិញ?

សែមៈ ដូរហ្នឹងអាច សុន សេន បញ្ជាទៅព្រោះអគ្គសេនាធិការចែកគ្នា របៀបថាចែកគ្នា សុន សេន កាលហ្នឹងដល់ឈប់ធ្វើអគ្គសេនាធិការហើយគាត់ឡើងទៅក្រសួងការបរទេស ជំនួសទៅជួយតា អៀង សារី វិញ។

ប៊ុនថនៈ អញ្ចឹង តាម៉ុក គាត់ឡើងទៅ

សែមៈ តាម៉ុក គាត់ឡើងជាអគ្គសេនាធិការជំនួស តាសុន សេន វិញ។

ប៊ុនថនៈ អញ្ចឹងបានគាត់ឡើងទៅខាងលង្វែង។

សែមៈ ហ្នឹងហើយអញ្ចឹងបានគាត់ឡើងទៅលង្វែងទៅបញ្ជាទ័ពនៅហ្នឹង តាសារឿន តាអីហ្នឹង កូនប្រសារគាត់ប្ដីច្រិចប្ដីអីសុទ្ធតែកងពល។

ប៊ុនថនៈ ពីណាគេពូ?

សែមៈ ប្ដីច្រិចហ្នឹង។

ប៊ុនថនៈ ឈ្មោះអី?

សែមៈ ឈ្មោះ ឈឿន ប្ដីច្រិច ហ្នឹងឈ្មោះ ឈឿន។

ប៊ុនថនៈ កូនតាម៉ុក ហ្នឹង?

សែមៈ បាទ! កូនប្រសារ។

ប៊ុនថនៈ កូនប្រសារ?

សែមៈ បាទ!

ប៊ុនថនៈ ស្អី ឈឿន?

សែមៈ មិនដឹងស្អី ឈឿន ទេខ្ញុំភ្លេចបាត់ហើយ មិនដឹងជាត្រកូលអីទេ ឈ្មោះ ឈឿន អញ្ចឹងហើយគាត់កងពលដែរ។

ប៊ុនថនៈ គាត់កងពលដែរ?

សែមៈ ហ្នឹងហើយ។

ប៊ុនថន៖ កងពលប៉ុន្មានពូ?

សែម៖ មិនដឹងកងពលប៉ុន្មានទេ ។

ប៊ុនថន៖ ម៉ា ឈឿន មែនពូ?

សែម៖ មិនដឹងជាម៉ា ឈឿន ឬក៏អី ឈឿន ទេ ។

ប៊ុនថន៖ គាត់នៅរស់ទេសព្វថ្ងៃ?

សែម៖ រាល់ថ្ងៃនៅរស់តើ កាលសមារណកម្មគាត់ចូលជាមួយរាជរដ្ឋាភិបាល គាត់កងពល ។

ប៊ុនថន៖ គាត់កងពល តែខាងនេះទេ?

សែម៖ បាទ! អតីតខ្មែរក្រហមដែរ កូនប្រសារ តាម៉ុក ។

ប៊ុនថន៖ អញ្ចឹង តាម៉ុក ចេញហ្នឹងពូនៅជាមួយពីណាវិញ ឬក៏ពូទៅជាមួយគាត់?

សែម៖ ពេល តាម៉ុក ទៅខាងជើងទៅខ្ញុំនៅជាមួយ តាឌួន រហូត នៅមន្ទីរគាត់ហ្នឹងរហូត នៅចាំកន្លែងចាំអី ចាំទូរស័ព្ទ ចាំគេអូអញ្ចឹងណា៎ ចាំទូរលេខ គេអត់ឲ្យទៅមុខទេព្រោះយើងធ្វើមិនកើត ។

ប៊ុនថន៖ ដូចជាពូត្រូវរបួសអញ្ចឹង ។

សែម៖ ហ្នឹងហើយយើងធ្លាក់ខ្លួនពិការ ។

ប៊ុនថន៖ ហើយនៅហ្នឹងខាងអ្នកណាគ្រប់គ្រងវិញ?

សែម៖ តាវ៉ែន ។

ប៊ុនថន៖ ខាងសំឡូតហ្នឹង តាវ៉ែន?

សែម៖ ប្រូកនេះ តាវ៉ែន ហើយពីក្រោយ តាប៉ុល ពត ហើយខាងសំឡូត បងម៉េត បងម៉េតយើងថ្នងវែងហ្នឹង ។

ប៊ុនថន៖ ស៊ូ ម៉េត ហ្នឹង?

សែម៖ មិនដឹងស៊ូ ម៉េត ទេខ្ញុំភ្លេចបាត់ហើយត្រកូលគាត់ ។

ប៊ុនថន៖ ស៊ូ ម៉េត ហ្នឹងឬក៏មិនមែនទេ?

សែម៖ មិនដឹងអី ម៉េត ។

ប៊ុនថន៖ ម៉ង់ ម៉េត?

សែម៖ មិនមែនទេ ខ្ញុំភ្លេចត្រកូលហើយនេះ នៅសំឡូតហ្នឹងមានបង ម៉េត ហើយមានអីទៀតទេមានច្រើនណាស់នៅហ្នឹង អាហ្នឹងមួយផ្នែកសំឡូតហ្នឹង ហើយប៉ៃលិនហ្នឹងមាន អ៊ី ឈានទៅ ប៉ុន្តែមកប្រជុំនៅត្រាតហ្នឹងទាំងអស់ ព្រោះប៉ុល ពត នៅនេះ អញ្ចឹងពេលប្រជុំមកនេះទាំងអស់ ហើយតាវ៉ែន ពួកនៅភ្នំស្រួច អ៊ំសាន អ៊ំអី ។

ប៊ុនថន: អ៎! អឹសាន នៅខាងវង្វង់មូលនេះហ្នឹងមែន?

សែម: បាទ! អឹសាន ហ្នឹង ។

ប៊ុនថន: កាលមុនគាត់ធ្វើអី?

សែម: ការពិតគាត់គណៈតំបន់ ។

ប៊ុនថន: គណៈតំបន់ប៉ុន្មាន?

សែម: មិនដឹងប៉ុន្មានទេ ។

ប៊ុនថន: ខាងបច្ចឹមមែនពូ?

សែម: ហ្នឹងហើយខាងបច្ចឹម គាត់ខ្មែរខាងភ្នំស្រួច ភ្នំស្រួចយើងខាងទឹកផុស អេ៎មិនមែនទេ អឹសាន ហ្នឹងខ្មែរខាងភ្នំស្រួច មិនមែនខ្មែរទឹកផុសទេ ខ្មែរទឹកផុសខាងខ្មែរវៃខាងអីទេ បងពន្ទក បងអីអាហ្នឹងនៅខ្មែរទឹកផុស នៅម្តុំៗគ្នាគាត់ហ្នឹង ។

ប៊ុនថន: អឹសាន ដល់ពេលក្រោយមកគាត់ខាងកងពលដែរ ពេលក្រោយមក៧៩ហើយហ្នឹង?

សែម: គាត់ជាប់ ដល់ពេលនេះមក អេ៎គាត់អត់មានជាប់អីទេ ការពិតគាត់ជាប់នេះហ្នង ជាប់នៅ កន្លែងស្រុកភូមិគាត់ គាត់នាំទ័ពចេញចូល គាត់ទៅធ្វើការជាមួយប្រជាពលរដ្ឋ ការងារ របៀបថាឃោសនាប្រជាពលរដ្ឋអញ្ចឹងណា៎ អត់មានទៅវៃទៅតប់អីនឹងគេទេគាត់ហ្នឹង ។

ប៊ុនថន: ចង់និយាយថាតួនាទីដល់ពេលក្រោយមក?

សែម: តួនាទីមិនដឹងជាប្រកាសគាត់អី ព្រោះអត់មានជាប់ខ្មែរខាងអីទេគាត់ហ្នឹង ព្រោះគាត់ហ្នឹង តាមមើលឃោសនាប្រជាជនហ្នឹងហ្នង ទៅឃោសនាអញ្ចេះឃោសនាអញ្ចោះ ។

ប៊ុនថន: ឲ្យសមារណកម្មហ្នឹងពូ?

សែម: បាទ! គាត់អញ្ចឹង ប៉ុន្តែដល់ពេលមកនៅស្រុករាល់ថ្ងៃនេះ តែឥឡូវគាត់អាត្រែត កាលមុន នោះចូលខាងប្រធានបក្ស បក្សស្រុកហ្នឹងគាត់ប្រធាន ការពិតគាត់ចូលបក្សហ្នឹងតាំងពី ឆ្នាំ៥៤ អញ្ចឹងបានប្រមូលបក្សៗហ្នឹងឲ្យគាត់ហ្នឹងធ្វើប្រធានវិញដដែល គាត់ចាស់ជាងគេ តែឥឡូវគាត់អាត្រែតហើយ ។

ប៊ុនថន: ខ្ញុំជួបគាត់តើ ជួបគាត់កាលពីម្សិលមិញ គាត់ដឹងច្រើនដែរ ។ ហើយលោកពូនៅម្ខាងមន្ទីរ នេះនៅខាងមួយប៉ែកពូហ្នឹង ម៉េត អ្នកគ្រប់គ្រង?

សែម: អត់ទេ ការពិតនៅយើងសំឡូត តែក្រោមការបង្គាប់បញ្ជារបស់ប៉ុល ពត ដដែលនៅកន្លែង ហ្នឹងការពារប៉ុល ពត ដដែល ប៉ុន្តែគ្រាន់តែមន្ទីរខាងខ្ញុំហ្នឹងខាងកងទ័ពហ្នង ហើយគៀកគ្នា ជាមួយកន្លែងសុខសាន្តៗនេះ កាលហ្នឹងនៅព្រំវត្តព្រំអីគេនៅជាប់គ្នាហ្នឹងគេសហការណ៍

ជាមួយហ៊ុន សុិនប៊ិច អ៉ំមិនមែនហ៊ុន សុិនប៊ិច ទេគឺ សេរីការ ខ្សែខាងសុន សាន ព្រំវត្តហ្នឹង គេនៅជាប់ជាមួយគ្នា គេសហការណ៍គ្នា ។

ប៊ុនថនៈ ជាប់ជាមួយអន្តភាព...?

សែមៈ ជាប់ជាមួយអន្តភាពរបស់ខ្ញុំហ្នឹង ជាមួយ ឆ្នូន ជាមួយអីហ្នឹង ហើយខ្ញុំនៅខាងក្រៅចេញចូលអីតាមហ្នឹង ។

ប៊ុនថនៈ អញ្ចឹងទំនាក់ទំនងគ្នា?

សែមៈ បាទ ។

ប៊ុនថនៈ ប៉ុន្តែអត់អីទេជាមួយខាង សេរីកា ហ្នឹង?

សែមៈ អត់អីទេ កាលហ្នឹងយើងទៅណាមកណាអីអញ្ចឹងទៅ យើងចេញចូលកន្លែងគេ គេចេញចូលកន្លែងយើង យើងប្រាប់គ្នាទៅវិញទៅមក ហើយការពិតម្ដុំកូនចៅខាងព្រំវត្តភាគច្រើនសុទ្ធតែពីទ័ពយើងអ្នកដែលបាក់រត់យួនវៃហ្នឹង ហើយគាត់ជ្រើសរើសយកកម្លាំងហ្នឹងទុកហ្នឹងអ្នកស្គាល់ៗគ្នារបៀបថាមនុស្សស្គាល់គ្នា តែបើរឿងកិច្ចការណាផ្សេងអាហ្នឹងជារឿងរបស់មេៗទេ អាយើងអ្នកស្គាល់គ្នានិយាយរកគ្នាទៅវិញទៅមកធម្មតា ។

ប៊ុនថនៈ អញ្ចឹងព្រំវត្តហ្នឹងគាត់កាន់ខាងនេះដែរ?

សែមៈ គាត់កាន់មួយកន្លែងដែរ គាត់កាន់ម៉ាជំរុំដែរ ដែលគេហៅថាជំរុំសុខសាន្តហ្នឹង ។

ប៊ុនថនៈ នៅខេត្តណាពូ?

សែមៈ នៅត្រាតដែរហ្នឹង បើយើងនៅស្រុកថៃណា៎ ។

ប៊ុនថនៈ ជាប់ព្រំប្រទល់ខេត្តណា?

សែមៈ ជាប់ព្រំប្រទល់ខេត្តបាត់ដំបង កន្លែងហ្នឹងកន្លែងទីតាំងគេ គេដាក់ឈ្មោះជំរុំសុខសាន្តអីគេហ្នឹង ជំរុំហ្នឹងតាំងពីយូមកហើយ តាំងពីជំនាន់អតីតខ្មែរក្រហម ជំរុំហ្នឹងមិនដឹងកើតតាំងពីណាមក

ប៊ុនថនៈ អញ្ចឹងព្រំវត្តហ្នឹងគាត់ខាងបញ្ជាការនៅហ្នឹងដែរ?

សែមៈ បាទ! ខាងបញ្ជាការនៅហ្នឹង ។

ប៊ុនថនៈ នៅសេរីការហ្នឹងដែរ?

សមៈ បាទ!

ប៊ុនថនៈ អញ្ចឹងទំនាក់ទំនងជាមួយខាងពូនៅសំឡូតនេះដែរ?

សែមៈ បាទ! គ្រាន់តែពេល កាលហ្នឹងត្រីភាគីនាំគ្នាវៃយួនទាំងអស់ គេវៃតាមមុខគេទៅ គេវៃឡើងទៅមងទៅអីអញ្ចឹងទៅ ហើយយើងហ្នឹងបើមានមុខសញ្ញាអី កងទ័ពអីទៅក្នុងទៅអីអញ្ចេះអញ្ចុះតាមមុខកន្លែងយើងនៅអីយើងគ្រាន់ការពារកន្លែងយើងទៅ ចេញចូលអីធម្មតា

ទៅ ហើយ តាឌួន កាលហ្នឹងគេឲ្យគាត់ប្រចាំការនៅទីតាំងព្រំដែន ដើម្បីការពារមនុស្សចេញមនុស្សចូល សកម្មភាពកើតឡើងក្រោយអីហ្នឹង អាហ្នឹងរបៀបដូចថាការពារប៉ុល ពតដែរហ្នឹង ព្រោះអត់មាននេះណា មានទៅវៃក្នុងណា៎ គ្រាន់តែការពារអញ្ចឹង មនុស្សចេញមនុស្សចូល មនុស្សដឹកជញ្ជូនដើរទៅមកអី របៀបប្រចាំច្រកអញ្ចឹងណា៎ ប្រចាំច្រកឲ្យមនុស្សចេញចូល ព្រោះកម្លាំងដឹកជញ្ជូនចេញចូលទៅមកអីតាមហ្នឹង ។

ប៊ុនថន៖ អាហ្នឹងគេអត់មានដាក់ឈ្មោះអីទេ គេហៅមន្ទីរអញ្ចឹងហ្មង់ពូ គេហៅមន្ទីរអី?

សែម៖ កន្លែងគេមួយៗគេដាក់ ឧទាហរណ៍ថាខ្ញុំនៅជាប់មន្ទីរ តាឌួន ហ្នឹង តាឌួន ហ្នឹងកងពលដែរ ។

ប៊ុនថន៖ កងពលប៉ុន្មាន តាឌួន?

សែម៖ កាលហ្នឹងកងពលទី២ ។

ប៊ុនថន៖ កងពលទី២?

សែម៖ បាទ!

ប៊ុនថន៖ ចុះក្រោមគាត់ពីណាគេ ក្រោម តាឌួន?

សែម៖ ក្រោមគាត់មានវរៈសេនាធំ តែបែកបាក់គ្នាអស់ហើយ តាឈឿង អីហ្នឹងស្លាប់អស់ហើយ ណាណីអីស្លាប់អស់ហើយ ប៉ុន្តែកងពលហ្នឹងក្រោយមកគេរំលាយ កងពលទី២ហ្នឹងក្រោយមកគេរំលាយ ដល់ពេលគេរំលាយហើយគេបូកបញ្ចូលគ្នាទាំងពលទី២ហើយពលទី៣ហ្នឹងបូកចូលគ្នា គេហៅកងពលទី៥វិញ ពីបូកនឹងបីទៅគេហៅកងពលទី៥ អញ្ចឹងគណៈបញ្ជាការរួមនោះដឹកនាំដោយ ឈឿន យើងនេះ ឈឿន ហ្នឹងនៅប៉ុង ឈឿន ខ្វាក់ហ្នឹង មេកងពលហើយ តាឌួន ហ្នឹងរង ហើយ តាតូយតាអីហ្នឹងរង កងពលប៉ុន្មានតែគ្នា៤-៥នាក់ហ្នឹងព្រោះអស់មេ មុនដំបូងកងពលទី២ហ្នឹងការពិតឈ្មោះ ធី គាត់អ្នកគ្រប់គ្រង គេហៅធីពោះសេ ហ្នឹង ដល់ពេលស្លាប់ ធី ហ្នឹងទៅបាន ឌួន ដល់ពេលស្លាប់ ធី អញ្ចឹងទៅ ដល់ក្រោយមកមនុស្សវាតិចទៅកងពលហ្នឹងគេបញ្ចូលកងពលលេខ២ហើយលេខ៣ហ្នឹងបូកបញ្ចូលគ្នាទៅជា៥អញ្ចឹងណា៎ ។

ប៊ុនថន៖ អញ្ចឹងបូកបញ្ចូលគ្នាដាក់លេខ៥អញ្ចឹងហ្មង់?

សែម៖ បាទ! ហើយគេឲ្យប្រចាំនៅព្រំដែនហ្នឹងរហូត វាអត់ឲ្យទៅក្នុងទៅណាមកណាទេ វាឲ្យនៅតែចាំគ្រាន់ការពារព្រំដែនហ្នឹង សូម្បីតែក្នុងប្រហោងទៅដល់ក្នុងជ្រៅក៏ដោយក៏នៅអគ្គភាពហ្នឹងនៅព្រំដែនហ្នឹងដែរ ព្រោះច្រកគេឲ្យការពារឃ្លាំងការពារអី ការពារទ្រព្យ ឥវ៉ាន់អីត្រូវដឹកពី

ចិន ដូចគ្រាប់កាំភ្លើងតូចកាំភ្លើងធំអីយកមកដាក់នៅឃ្លាំងហ្នឹងការពារហ្នឹង រួមជាមួយជនជាតិណាំ ជាមួយជនជាតិពួក តាកែន ហ្នឹង ។

ប៊ុនថន: តាកែន គណៈមន្ទីរ៨៧០ ហ្នឹងមែន?

សែម: ហ្នឹងហើយ ។

ប៊ុនថន: អញ្ចឹងតាៗអាសារទៅហ្នឹងដែរពូ គាត់អាសារទៅមន្ទីរដែរ?

សែម: តាៗអស់ហ្នឹងទៅ ប៉ុល ពត ហៅព្រឹកគ្រាតៗល្ងាចអញ្ចឹងទៅ ព្រោះមានទៅឆ្ងាយប៉ុន្មានពីព្រំដែនទៅគ្រាតហ្នឹង ជិះឡានកន្លះម៉ោងអីដល់គ្រាតហើយ ឥឡូវពីនេះទៅដីព្រំដែនពីនេះទៅប៉ុន្មាន បើខ្សែត្រង់១៣គីឡូហ្នឹង ពីនេះទៅរាល់ថ្ងៃហ្នឹង ហើយពីព្រំដែនទៅគ្រាតហ្នឹងប៉ុន្មានវាឆ្ងាយប៉ុនគ្រាន់តែឡានចុះទៅថៃហើយផ្លូវជាតិវាលឿនសឹងអី កន្លះម៉ោងអីដល់បាត់ហើយកន្លែងប៉ុល ពត ។

ប៊ុនថន: អញ្ចឹងតាៗអាសាមកហ្នឹងដែរ?

សែម: បាទ! ទៅមកៗ ។

ប៊ុនថន: មានពីណាខ្លះ មានប៉ុល ពត ហើយមានពីណាទៀត?

សែម: ប៉ុល ពត គេមិនសូវមកទេ ។

ប៊ុនថន: ចុះមកញឹកជាងគេពីណាគេ?

សែម: ញឹកជាងគេគឺ តានួន ព្រោះតានួន មុខសញ្ញាគាត់ប្រចាំនៅសំឡូត ដល់ពេលត្រូវការអីគាត់ត្រូវការនេះគាត់អត់ចុះដីថៃទេ គាត់ដើរតាមព្រំដែនទៅមកៗ តានួន ទៅមកៗ ហើយមានតាម៉ុក ហ្នឹងមិនបាច់ចាំអ្នកណាឃាត់ទេ មិនបាច់ចាំថាអ្នកណាអីអ៎! អត់ឲ្យគាត់ដើរពីបីនាក់ទេ ។

ប៊ុនថន: គាត់អាសារមក?

សែម: បាទ! ដល់កន្លែងណាបាយកន្លែងហ្នឹង ចូលផ្ទះគេកន្លែងទ័ពកន្លែងអីហ្នឹង ចូលដាំបាយដាំអីរកបាយរកអីទៅ រកម្ហូបគេហ្នឹងទៅ ហើយទៅទៀតទៅ ហើយមិនបាច់សួរថាគាត់ទៅណាមកណាគាត់ទៅៗ អត់មានអ្នកណាការពារ អត់មានអ្នកណា មានតែតាម៉ុក ហ្នឹងទេដែល...។

ប៊ុនថន: គាត់ដើរអត់ខ្លាចទេ?

សែម: គាត់អត់ខ្លាចទេ ព្រោះទៅខ្លាចអី បើពិនិត្យទៅ ទៅណាក៏គេស្គាល់ ភាគច្រើនគេស្គាល់គាត់គ្រប់គ្នា ដល់ពេលនេះគេថាអ៎ តាមកហើយ អ៊ឹមកហើយបានអីស៊ី ហើយគាត់ចូលចិត្ត

ណាស់បើមានស្វា បាញ់ស្វាបាញ់អី ហើយគាត់សួរមានអ្នកណាបាញ់ស្វាបានអត់ ឯងយកមកដូរត្រីខអញវ៉ើយ ។

ប៊ុនថន: អ៎! គាត់ហូបអញ្ចឹងៗដែរ?

សែម: គាត់ហូបតែអញ្ចឹង ហូបស្វា ហូបជ្រូកព្រៃហូបអីហ្នឹង គាត់ចូលចិត្តណាស់រឿងស្វារឿងអីហ្នឹង បើថាដំរី ទន្សោង ខ្ទីង អីហ្នឹងអត់ទេ បើថាស្វាគាត់ចូលចិត្តហូបណាស់ មិនដឹងម៉េចគាត់ ។

ប៊ុនថន: តែសត្វព្រៃអីគាត់អត់ចូលចិត្តទេ?

សែម: សត្វព្រៃអីគាត់អត់សូវទេ ។

ប៊ុនថន: ម៉េចបានជាគាត់អត់ហូបទន្សោង?

សែម: មិនដឹងជាម៉េច គាត់ថារោគគាត់អត់ត្រូវ បើហូបស្វាគាត់ថាស្រួល បើហូបសាច់អញ្ចឹងគាត់ថាអត់ ព្រោះគាត់ហូបហើយច្រើនតែគាត់ថា បើគាត់ហូបអញ្ចឹងទៅឲ្យពេទ្យពិនិត្យភាគច្រើនច្រើនតែខ្លាញ់ក្នុងសរសៃឈាម គាត់ថាអញ្ចឹង អញ្ចឹងគាត់ចូលចិត្តហូបតែស្វា ហូបត្រីហូបអីអញ្ចឹងវិញ អញ្ចឹងទេគាត់រកត្រីរកអីទៅ ។

ប៊ុនថន: ចុះពូនៅខាងទំនាក់ទំនង ដូចថាទំនាក់ទំនងជាមួយខាងសេរីការ ជាមួយ តាវិត ឈ្មោះព្រំ វិត ហ្នឹង ព្រំ វិត ហ្នឹងគាត់បញ្ជាការដែរពូកាលហ្នឹង?

សែម: ព្រំ វិត ហ្នឹងអាចបញ្ជាការ បញ្ជាការកន្លែងគេហ្នឹងមួយ ព្រោះកន្លែងសុខសាន្តហ្នឹងមានតែព្រំ វិត ហ្នឹងទេគាត់ទៅមក មានអាត្រាក់មានអី ពេលណានេះគាត់ ប៉ុន្តែមិនដែលមានឃើញសហការណ៍វៃចូលគ្នាទេណ៎ ព្រំ វិត គេត្រូវទៅណា ដូចថាទៅមងទៅអីអញ្ចឹងគេទៅវៃតែគេហ្នឹងទៅ ចេញចូលតាមកន្លែងយើងធម្មតា ។

ប៊ុនថន: ប៉ុន្តែកម្លាំងពូទាក់ទងហ្នឹងមានតែខាងពូខាងសំឡូតទេ ផ្នែកផ្សេងៗមានទាក់ទងគ្នាទេ?

សែម: កម្លាំងខាងអតីតខ្មែរក្រហមយើងអត់អីទេ ។

ប៊ុនថន: ខាងសេរីការ?

សែម: ខាងសេរីការក៏អត់អីដែរ ទៅមកធម្មតា ខាងសំឡូតក៏គេអញ្ចឹងដូចគ្នា ទៅណាមកណាគ្រាន់តែគេឃើញគេដឹង ប៉ុន្តែគ្រាន់តែក្នុងហ្នឹងគេប្រាប់ដែរណ៎ យើងចេញចូលអី ធ្វើដំណើរកាត់កន្លែងយើងគ្រប់គ្រងអីគេទាក់ទងយើងដែរ ដូចថាខ្ញុំមកដល់នេះមកដល់នោះហើយ មើលផង កុំប្រឡំអីអញ្ចឹងណ៎ ។

ប៊ុនថន: ចុះពូនៅមន្ទីរហ្នឹង ពូស្គាល់ជិតស្និទ្ធជាងគេ តាម៉ុក មែនពូ?

សែម: តាម៉ុក គាត់អាសារចេញចូលមកដល់កន្លែងខ្ញុំអញ្ចឹងមក រកអីហូបគាត់ចូលមក ។

ប៊ុនថន៖ គាត់ដែលនិយាយលេងជាមួយពួទេ?

សែម៖ និយាយលេងធម្មតា សាមញ្ញ គាត់សួរសុខទុក្ខយើងម៉េចហើយ សួរសុខសប្បាយទេ ហើយពួកហ្នឹងដើរទៅអញ្ចឹងមើលយើង នែវ៉ើយ លាងឆ្នាំងលាងចានឲ្យត្រឹមត្រូវស្អាតបាត គ្រុនណាស់ គាត់ណែនាំយើងអញ្ចឹងទៅ បើមិនអញ្ចឹងដល់ម៉ោងបាយគាត់ គាត់រកបាយរកអីហូបទាំងអស់គ្នាហ្នឹងទៅ ។

ប៊ុនថន៖ ប៉ុន្តែដូចថាគាត់មានដែលនិយាយរឿងគាត់ រឿងការងាររបស់គាត់អីប្រាប់ក្មេងៗទេ?

សែម៖ គាត់និយាយពីរឿងល្អ គាត់មិនដែលនិយាយពីរឿងធ្វើបាបអ្នកណាទេ ទាំងអស់គ្នាដែលធ្លាប់ស្គាល់គាត់មក មិនដែលឃើញគាម៉ុក ទៅបាញ់អ្នកណាមួយឲ្យរបួសបុក៏ម៉េចទេ ។

ប៊ុនថន៖ ប៉ុន្តែដូចថាគាត់ដែលនិយាយរឿងការងារ ដូចថាមានស្លាប់មានអីអញ្ចឹងណា៎?

សែម៖ គាត់និយាយដែរ គាត់និយាយថាគេអ្នកប្រព្រឹត្តគេអ្នកធ្វើ តែដល់ តែការពិតគាត់ទើបតែឡើងដែរ កាលពីមុនមកគាត់គណៈភូមិភាគហ្នឹង ប៉ុន្តែដល់ក្រោយមកគាត់ទើបតែឡើងមកដល់ពេលនេះគាត់ថាគេអ្នកធ្វើមុនគេនាំអាគត្ឲ្យ គាត់និយាយដែររបៀបប្រវត្តិសាស្រ្ត គាត់ដឹងខ្លួនដែរការពិត ដល់ក្រោយមកបានព្កគាត់និយាយ គាត់ថាកាលសម័យមុនគាត់មិនដែលបានដឹងដែរ ទើបក្រោយមកបានព្កគេថាសម្លាប់មនុស្ស សម្លាប់ច្រើនអញ្ចឹងណា៎ អាហ្នឹងគាត់និយាយខ្លួនគាត់ ។

ប៊ុនថន៖ ប៉ុន្តែគាត់ថាអ្នកផ្សេង?

សែម៖ បាទ! ប៉ុន្តែខ្លួនគាត់បើខ្ញុំពិនិត្យទៅដូចមិនដែលឃើញមានសកម្មភាព មិនមែនថាយ៉ាងម៉េចទេ មិនដែលគាត់កាន់កាំភ្លើងកាន់អី មានតែគាត់ណែនាំថា នែប្រយ័ត្នប្រយ៉ែង ធ្វើនេះធ្វើនោះ ប្រយ័ត្នគ្រោះថ្នាក់ មានតែណែនាំយើងឲ្យល្អ អត់ដែលនិយាយពីរឿងអញ្ចេះអញ្ចុះទេ គាត់ដែលនេះជាមួយអ្នកណាទេ ហើយគាត់នៅកន្លែងណា បើយើងតាមដានបុក៏អីម៉េច ប៉ុន្តែគ្រាន់តែដាក់ស្តែងភ្នែកខ្ញុំបានឃើញ គាត់មិនដែលបានទៅប្រព្រឹត្តលើអ្នកណាឲ្យហូរឈាមអីអត់ទេ ។

ប៊ុនថន៖ ចុះ តាឌួន?

សែម៖ តាឌួន ក៏អញ្ចឹង ប៉ុន្តែគ្រាន់តែ តាឌួន ហើយនឹងខ្ញុំដូចខ្ញុំជម្រាបអញ្ចឹង ដូចថាមិនអាចចូលកន្លែងគាត់បានសេរីបានទេណា៎ ហើយគាត់មានកន្លែងផ្សេង គាត់ទៅនៅត្រង់ណាស្ងាត់ស្ងៀម មានតែជនជាតិយាមមិនឲ្យយើងចូលទេ ហើយមិនសូវឲ្យយើងជួបទេ ពេលគាត់ធ្វើដំណើរទៅណាមកណាមានអង្គរក្សគេដើរមុនគេប្រាប់ នែអឹមកហើយ នាំគ្នាចូលព្រៃ

ទៅ ហើយយើងនាំគ្នាចូលព្រៃទៅ គាត់ធ្វើដំណើរតែគាត់ទៅ ហើយគេឃ្លាំមើលខ្លាចយើងទៅជួបទៅអីអញ្ចេះអញ្ចុះ ។

ប៊ុនថន: ចុះលោកពូរៀបការនៅឆ្នាំណា កាលការជាមួយមីង?

សែម: ខ្ញុំដូចជា៨៤ ។

ប៊ុនថន: ៨៤?

សែម: បាទ!

ប៊ុនថន: ការហើយពូនៅមន្ទីរហ្នឹងដដែល?

សែម: បាទ! ការហើយនៅមន្ទីរហ្នឹងដដែល ។

ប៊ុនថន: ហើយពូមានដែលដូរទៅណាទៀតទេ?

សែម: កាលមុនខ្ញុំនៅហ្នឹង ដល់ពេលក្រោយមកគេរៀបចំ ម៉េត អីហ្នឹងគេរៀបចំដែនការណ៍របស់ព្រំដែនហ្នឹង របស់តាម៉ុក ហើយតាសុន សេនអីហ្នឹង គេរៀបដែនការណ៍គេលក់ឈើ គេលក់ឈើមួយជួរនេះ ។

ប៊ុនថន: មួយជួរណាពូ?

សែម: មួយជួរហ្នឹង កាលពីមុនមកឈើសម្បើមណាស់ ប៉ុន្តែក្រោយមកគេហៅថាដែនការណ៍គណៈប្រូកគេលក់ឈើនៅនេះ ដល់ពេលគេលក់ឈើអញ្ចឹង គេឲ្យថៃចុះមកកាប់ ដល់ពេលអញ្ចឹងគេរៀបរយឲ្យខ្ញុំមកវាស់ឈើវាស់អីនឹងគេ អញ្ចឹងបានខ្ញុំនៅ កាលមុនខ្ញុំនៅផ្ទះហើយខ្ញុំវាស់ឈើវាស់អីលក់ឈើម៉ាជួរហ្នឹងឲ្យថៃ ប៉ុន្តែកាលដែលលក់ហ្នឹងគេដាក់ គេណែនាំ មាស មុតគេណែនាំឲ្យថៃកាប់ដើមទំហំប៉ុន្មាន ប្រយ័ត្នដល់ពេលថ្ងៃក្រោយក្មេងៗគេថាយើងហ្នឹងលក់ឈើឲ្យថៃ លក់ជាតិ លក់ទឹក លក់ដី មានតែណែនាំអញ្ចឹងណា៎ ហើយកាត់ហ្នឹងមានទំហំប៉ុន្មាន ឧទាហរណ៍ថាដើមជុំ៤០០អីបានឲ្យកាប់ យើងវាស់អញ្ចឹងទៅជុំ៣០០-៤០០អីបានឲ្យកាប់ ដើមតូចៗអត់ឲ្យកាប់ទេ ។

ប៊ុនថន: កាប់ពីណាដល់ណាគេបើក ប្រូកកាលហ្នឹង?

សែម: កាលហ្នឹងម៉ាព្រៃក្រវ៉ាញហ្នឹងទាំងអស់ កាត់ទៅឆ្ងាយដល់លៀង ឆ្ងាយដល់ស្ពង់អី ប៉ុន្តែថៃវាច្រើន ហើយកាលហ្នឹងបើតាមខ្ញុំដឹងអញ្ចេះ ឈើយើងមិនមែនលក់អតីតខ្មែរក្រហមយើងនេះទេ តាមពិតរដ្ឋាភិបាលកាលហ្នឹងអតីតខ្មែរក្រហមលក់នេះ ២ពាន់ទៅ ដល់ទៅដល់៦ព្រលានចុះទៅជិតត្រាត ខាងរដ្ឋាភិបាលគេវាស់មួយផ្នែក អញ្ចឹងបូកចូលគ្នាយើងនេះលក់២ពាន់ ហើយគេនោះលក់២ពាន់ដែរឡើង៤ពាន់ ។

ប៊ុនថន: ម៉េចក៏ចូលគ្នាជាមួយខាងរដ្ឋាភិបាល?

សែមៈ ចូលគ្នាហ្នឹងថៃវានិយាយអញ្ចេះ បើសិនជាអត់ចូលជាមួយរដ្ឋាភិបាលអត់មានទង់ អាទង់ពេលវាដឹកទៅម៉ាឡេទៅអីហ្នឹងអត់មានទង់ខ្មែរទេ គេថាអញ្ចឹងណ៎ា ទាល់តែលក់ឲ្យយើងខាងអតីតខ្មែរក្រហមនេះផង លក់ឲ្យខាងរដ្ឋាភិបាលផងបានមានទង់បង្គួត វាដឹកទៅមានទង់នាំចេញពីខ្មែរ គេនិយាយអញ្ចឹង ដូចច្បាប់គេគឺគេទទួលស្គាល់អញ្ចឹង គេនិយាយអញ្ចឹងខ្ញុំមិនដឹងដែរ អាហ្នឹងថៃគេនិយាយ បើទិញតែពីអតីតខ្មែរក្រហមនេះវាអត់ហ៊ានដឹកចេញទៅ ទាល់តែមានទង់ពីរដ្ឋាភិបាលផងបានទៅរួច អាហ្នឹងគេនិយាយអញ្ចឹង តែខ្ញុំជាក់ស្តែងខ្ញុំចុះទៅមើលជាមួយថៃមែន ឃើញគេវាស់ អញ្ចឹងគេគិតហ្នឹង ខាងរដ្ឋាភិបាលលក់ភាគហ៊ុនស្មើគ្នាហ្នឹងលក់២ពាន់ គេនោះលក់២ពាន់ដែរ ដល់ពេលបូកលុយមកឲ្យមកយើង២ពាន់ ហើយឲ្យទៅរដ្ឋាភិបាល២ពាន់ ។

ប៊ុនថនៈ ចុះអ្នកណាដូចថាអ្នកមើលក្តោប គ្រប់គ្រង?

សែមៈ ក្តោបនៅអតីតខ្មែរក្រហម តាម៉េត ។

ប៊ុនថនៈ ស៊ូ ម៉េត?

សែមៈ បាទ! តាម៉េត យើងសំឡូតហ្នឹង ប្រធានរួមអ្នកលក់ឈើ ។

ប៊ុនថនៈ ស៊ូ ម៉េត ហ្នឹងកាលមុនគាត់អីវិញពូ?

សែមៈ កងពល ការពិតខ្ញុំស្គាល់យូហើយ ស្គាល់តាំងពី៧២ គាត់កងពលតាំងពី៧២ ។

ប៊ុនថនៈ គាត់កងពលអាកាសមែនពូ កាលសម័យពន្សាំ?

សែមៈ កងពលថ្មើរជើង កាលហ្នឹងយើងអត់ទាន់មានបង្កើតកងអាកាស កងរថក្រោះអីទេ ទេព្រោះតាំងពី៧៣មកយើងមានតែថ្មើរជើងទេ អត់មានកងរថក្រោះកងអីៗទេ មានតែអន្តរាគមន៍

ប៊ុនថនៈ ដល់ពេលបែកហើយ?

សែមៈ ដល់បែកហើយបានគេរំលែកគ្នា គេបែកគ្នា ចាំមើល៧៦ចុង៧៥បើតាមខ្ញុំដឹងគេបែកគ្នាភូមិភាគបច្ចឹមហ្នឹងគេបែកគ្នាដូចខ្ញុំថាម៉េញហ្នឹង កងរថក្រោះផង ជើងអាកាសផង ហើយជើងទឹកទៀត ហើយមកភូមិភាគបូព៌ា ភូមិភាគកណ្តាលហ្នឹងថ្មើរទាំងអស់កងទ័ព ។

ប៊ុនថនៈ អញ្ចឹងស៊ូ ម៉េត ហ្នឹងគាត់ខាងគោកហើយខាងអាកាស?

សែមៈ មិនដឹងជាគាត់ កាលហ្នឹងបែកគ្នាទៅ កាលវើហ្នឹងនៅជុំគ្នា ដល់ពេលខ្ញុំទៅក្រចេះហ្នឹងទៅតាមពិតអត់ដឹងថាគាត់យ៉ាងម៉េចទេ ដឹងគ្រាន់ថាក្នុងហ្នឹងអាចមានបញ្ចូល តាលៃ ពន្ទកណាណាំចូលក្នុងហ្នឹងច្រើន កងពល៥០២ហ្នឹង ហើយមិនដឹងជាគាត់ទៅខាងណាខាងណាំ ខាងរថក្រោះខាងអីខ្ញុំមិនច្បាស់ដែរ ប៉ុន្តែដឹងត្រង់ថាបានមកព្រំដែននេះវិញបានដឹងថា ម៉េត ហ្នឹងកងពលតាំងពីឆ្នាំ៧៣ ។

ប៊ុនថន៖ គាត់អ្នកបើកច្រកហ្នឹងហ្មង?

សែម៖ បាទ!

ប៊ុនថន៖ អញ្ចឹងលោកពូដឹងពេលទៅជួបគ្នាពេលកាប់ឈើបើកច្រកហ្នឹងលោកពូ?

សែម៖ មកជួបបង ម៉េត ហ្នឹងជួបយូហើយ កាលហ្នឹងខ្ញុំនៅ ស្គាល់ដឹងគ្រាន់ព្រុថាបង ម៉េត ហ្នឹង ការពិតដឹងស្គាល់តាំងពីឆ្នាំ៧៣មក ហើយគាត់ក៏ស្គាល់ខ្ញុំ ខ្ញុំក៏ស្គាល់គាត់ដែរ ហើយប្អូនៗ គាត់ក៏សំណេះសំណាលគ្នា ដល់ពេលមកបែកគ្នា តាៗរៀបចំឲ្យគាត់ទៅគ្រប់គ្រងកន្លែងត្បូង នៅសំឡូតហ្នឹងទៅ ដល់ឥឡូវក៏គាត់នៅឈរនៅហ្នឹងដដែលអត់មានទៅណាទេ នៅសំឡូត ស្រុកផ្ទះអីនៅហ្នឹងដដែល ។

ប៊ុនថន៖ អញ្ចឹងលោកពូមកខាងនេះ ការហើយលោកពូមកនៅខាងវាស់ឈើ?

សែម៖ ខ្ញុំមកនៅហ្នឹងដល់ពេល មើ! ខ្ញុំការហើយបានកូនពីរបី ការហើយបានកូនពីរបីខ្ញុំមកនេះ មកឆ្នាំ៩៨ ឆ្នាំ៩៨បានខ្ញុំមកនេះ ។

ប៊ុនថន៖ ពេលក្រោយបោះឆ្នោតហើយហ្នឹង?

សែម៖ បាទ! ក្រោយបោះឆ្នោតហើយបានខ្ញុំមកនេះ កាលហ្នឹងមិនអតីតខ្មែរក្រហមធ្វើពហិការចូល រួមការបោះឆ្នោតជាមួយរដ្ឋាភិបាលយើង ដល់ពេលអញ្ចឹងចាប់ផ្តើមនាំគ្នាលក់ឈើលក់អី ហ្នឹង ចាប់ផ្តើមមានគំនិតលក់ហើយ ប៉ុន្តែលក់ហ្នឹងក្នុងរដ្ឋាភិបាលផង ហើយមានអតីតខ្មែរ ក្រហមផង លក់ឈើហ្នឹងបូកបញ្ចូលគ្នា លក់ឈើហ្នឹង៩៣-៩៨ដល់៩៦ ដល់ពេលដល់ឆ្នាំ ៩៦បានធ្វើសមាហរណកម្ម អាហ្នឹងចាប់ផ្តើមបែកខ្ញែកគ្នាហើយ ខាងសំឡូតហើយនឹងនេះក៏ មិនសូវត្រូវគ្នា អត់សូវត្រូវទេបែកគ្នាហើយ ។

ប៊ុនថន៖ ខាងនេះខាងពីណាវិញ?

សែម៖ ខាងនេះ កែវ ពង់ ចុះមក កែវ ពង់ តាមពិតគាត់ធ្វើសមាហរណកម្មមុនគេ ។

ប៊ុនថន៖ គាត់ហ្នឹងឆ្នាំ៩១?

សែម៖ អាច៩១ អញ្ចឹងអតីតខ្មែរក្រហមមិនធ្វើពហិកម្មចូលរួមការបោះឆ្នោតរបស់ អ៊ុន គាត់ គាត់បំបែកខ្លួនចេញ គាត់នៅឱរ៉ាល់ អញ្ចឹងគាត់ធ្វើសមាហរណកម្មមុនគេ អញ្ចឹងដល់ពេល គាត់ធ្វើសមាហរណកម្មហើយគាត់បបួលកម្លាំងនៅនេះធ្វើសមាហរណកម្មតាមក្រោយ អញ្ចឹង បានថារឿងឈើហ្នឹងក៏អញ្ចឹងដែរ តាមពិតនៅដូចប៉ុន្មានទេ ដូចជា៤ពាន់គីប ដល់ពេល សភាពការណ៍អញ្ចឹងកែវ ពង់ គាត់ចុះមកគាត់ដណ្តើមយកឈើហ្នឹងទាំងអស់ លក់ឲ្យថៃគាត់ យកលុយទៅ អញ្ចឹងបានគាត់ធ្វើមហាសេដ្ឋីឡើងទៅ អញ្ចឹងបានអ្នកខ្លះគេទំនាស់ ដូចអៀម ផាន អីគាត់ទំនាស់ជាមួយកែវ ពង់ អារឿងលុយហ្នឹង៤ពាន់គីបនៅច«១»នៅចុះថៃហ្នឹង ។

ប៊ុនថន៖ អ៎! គាត់លក់ហើយគាត់យកលុយ?

សែម៖ ដល់ពេលគាត់ធ្វើសាមារណកម្មហើយ មិនសម្តេចហ៊ុន សែន បញ្ជាឲ្យគាត់មក ចុះមកអប់រំអតីតខ្មែរក្រហមហ្នឹងឲ្យធ្វើសាមារណកម្មដូចគ្នា ដល់ពេលហ្នឹងមិនវៃគ្នាម៉ាទ្រុល ត្រូវគ្នាហើយគ្រាន់ថាវៃគ្នាម៉ាទ្រុលដោយសារចែកភាគហ៊ុនឈើហ្នឹងអត់ស្មើគ្នា មេៗគេនាំវៃ ដូចអៀម ផាន នេះគេនាំវៃម៉ាទ្រុលហ្នឹងទៅ។

ប៊ុនថន៖ ប៉ុន្តែឈើហ្នឹងបានលើពីណាគេវិញ?

សែម៖ ឈើហ្នឹងបានលើកែវ ពន់ បើគាត់ទៅដល់ឈរហ្នឹង ថៃវាដឹកចុះទៅ អញ្ចឹងគិតលុយឲ្យមកកែវ ពន់ មក។

ប៊ុនថន៖ ហើយអៀម ផាន គាត់នៅខាងណា?

សែម៖ គាត់នៅខាងសំឡូត។

ប៊ុនថន៖ ខាងសំឡូត?

សែម៖ ហ្នឹងហើយ ហើយខាងនេះអត់មានអ្នកណានៅទេ មានតែ តាប៊ិត ដល់ក្រោយមក តាប៊ិតហ្នឹងអត់មានទ័ពមានអីទេ អាញ៉ើអាញ៉ៅដើរតែលគោល ដល់ពេលអញ្ចឹងបានកែវ ពន់ ហ្នឹងគាត់មកចុះជួយគ្រប់គ្រង។

ប៊ុនថន៖ អញ្ចឹង៩៨ពូនៅណាវិញ?

សែម៖ ៩៨ខ្ញុំនៅសំឡូត។

ប៊ុនថន៖ ហើយ៩៦បានមកដល់នេះ?

សែម៖ បាទ!

ប៊ុនថន៖ ចុះពេលប្រទុះប្រទះហ្នឹងពូនៅណាវិញ?

សែម៖ ប្រទុះប្រទះហ្នឹងកាលហ្នឹងពួកសំឡូតគេភៀសទៅ គេភៀសយកទៅអប់រំម្តងទៀត ទៅដាក់នៅជំរុំកាយ ហុង។

ប៊ុនថន៖ ភៀសពីហ្នឹងទៅ?

សែម៖ បាទ! ភៀសពីហ្នឹងទៅ ពួកសំឡូតកាលហ្នឹងគេខាងសំឡូត កាលធ្វើសាមារណកម្មពួកសំឡូតគេនៅទេ នៅខ្មែរក្រហមនៅឡើយ ដល់ពេលពួកសំឡូតហ្នឹងគេធ្វើសាមារណកម្មទៅកែវ ពន់ មកនេះ អញ្ចឹងគេបំបែកកម្លាំង ហើយគេភៀសកម្លាំងនេះកុំឲ្យកែវ ពន់ យក អាហ្នឹងវាទៅជាដណ្តើមកម្លាំងគ្នាណា៎ ដណ្តើមកម្លាំងអតីតខ្មែរក្រហមគ្នា។

ប៊ុនថន៖ កាលនោះខាងសំឡូតពីណាវិញ?

សែមៈ ខាងសំឡូតគឺ អ៊ី ឈាន ឲ្យកម្លាំងពីហ្នឹងទៅ ឲ្យតាគង់ នៅសំឡូត អ៊ី ឈាន ហ្នឹងឲ្យតាគង់ហ្នឹងមក ។

ប៊ុនថនៈ សូ ហុង ហ្នឹងមែន?

សែមៈ ឈ្មោះ គង់ តែមិនដឹងអីគង់ ទេ តែ គង់ ហ្នឹងឥឡូវបែបដាប់ទាហាន ។

ប៊ុនថនៈ ឲ្យគាត់មកកៀរនៅខាងហ្នឹងវិញ?

សែមៈ បាទ! មកកៀរនៅខាងនេះ ឲ្យកម្លាំងមក មកកៀរនេះ ហើយកែវ ពង់ នោះស្រវ៉ារឿងឈើអត់មានគិតរឿងកម្លាំង ប៉ុន្តែគ្រាន់ថានៅជាមួយគាត់បានមួយចំនួនដែរ ដល់ពេលអញ្ចឹងគេចាប់ផ្ដើមកៀរពីហ្នឹងទៅ យកទៅដាក់នៅជំរុំ ដាក់ជំរុំគ្រាន់តែបានពាក់កណ្ដាលផ្លូវ អៀម ផាន ហ្នឹងគេកៀរមនុស្សហ្នឹងឲ្យចុះជំរុំ អត់ឲ្យទៅជាមួយអ៊ី ឈាន ទេ គេស្ទាក់កុំឲ្យទៅ ហើយចេះតែឃោសនាថាកម្លាំងហ្នឹងនេះអស់ហើយ កម្លាំងហ្នឹងគេអត់ព្រមធ្វើសាមារណកម្មទេ កម្លាំងអ៊ី ឈាន ជាមួយអៀង សារី ហ្នឹងគេត្រូវគ្នាគេអត់ឲ្យយើង កុំឲ្យទៅគេឃោសនាអញ្ចឹង ដល់ពេលអញ្ចឹងគេកៀរមនុស្សហ្នឹងដាក់នៅជំរុំម្ដុំ ដណ្ដើមកម្លាំងគ្នា ។

ប៊ុនថនៈ អញ្ចឹងកែវ ពង់ ហ្នឹងក៏មកកៀរចូលរដ្ឋាភិបាល ហើយខាងអ៊ី ឈាន ក៏កៀរចូល?

សែមៈ បាទ! កៀរដែរ គេកៀរដណ្ដើមមនុស្សរៀងៗខ្លួន ប៉ុន្តែកែវ ពង់ នោះបើកងទ័ពយើងតិច សំខាន់ជាងគេរឿងឈើហ្នឹង វ៉ា៤ពាន់គីបនោះមិនមែនតិចណា៎ សំខាន់គេយកឈើហ្នឹងសិន ដល់ពេលមកមើលមនុស្សហ្នឹងគេកៀរយកទៅអស់អាលីង ដល់ក្រោយមកឈ្មោះប្រទូសប្រទះគ្នាបានសម្ដេចហ៊ុន សែន គាត់មកចុះសម្ពោធ យើងត្រូវរ៉ូវគ្នា ហើយបានចាប់ផ្ដើមធ្វើសាមារណកម្មត្រូវទៅ ដល់ពេលអញ្ចឹងកែវ ពង់ លែងហ៊ានមកអើតនេះ ទើបតែឥឡូវមក កាលមុនអត់ហ៊ានមកទេខ្លាចគេ ខ្លាចគេគុំរឿងលុយកាក់រឿងឈើ ។

ប៊ុនថនៈ អញ្ចឹងពូមកដល់នេះដំបូងគេបែងចែកយ៉ាងម៉េចទៅដីធ្លី?

សែមៈ ដីធ្លីអត់ទេ កាលហ្នឹងមានមិនទាន់មានសិទ្ធអីត្រង់ថាយ៉ាងម៉េចទេ រឿងដីធ្លីអីយើងធ្វើសាមារណកម្មជាមួយរដ្ឋាភិបាលហើយក៏នៅតែ តែគ្រាន់តែក្នុងហ្នឹងអភិបាលស្រុកគាត់ណែនាំថាអញ្ចេះ អ្នកនៅត្រង់ណា សម្ដេចហ៊ុន សែន បានប្រកាសថាអ្នកនៅត្រង់ណានៅត្រង់ហ្នឹង ហើយមិនដកឋាណន់ថារៈស័ក្ដទេ ហើយទ្រព្យសម្បត្តិក៏មិនដក អ្នកដែលមានទ្រព្យសម្បត្តិហើយមានឋាណន់ថារៈស័ក្ដគឺរក្សាទុកនៅដដែល ហើយអញ្ចឹងបានគាត់ណែនាំថាឲ្យមានដីមានធ្លី កាលនោះយើងនៅលើដីនេះ ការពិតវាទំនាស់បន្តិចរវាងដីពួកបរិស្ថាន ប៉ុន្តែបើប្រជាជនគាត់នៅយូមកហើយ ឧទាហរណ៍ដូចខ្ញុំអីមកនៅតាំងពីមុន ហើយពួកហ្នឹងទើបមកក្រោយ តែការស៊ីញ៉េពី៩៣ គេរាល់ថ្ងៃនោះប្រជាជនគាត់នៅហើយស្រេចហើយ

ប្រជាជននេះគោលការណ៍របស់សម្ដេចនាយកថាអ្នកនៅត្រង់ណានៅត្រង់ហ្នឹង ហើយការពារព្រំដែនផង ការពារបរទេសផង ពេលដែលវាមកជ្រៀតជ្រែកអញ្ចឹង បាននៅឈរថ្មដារឈរតគ្នាហ្នឹងទៅហើយបង្កើតជាស្ថាប័នស្រុកវាលវែងយើងទៅ ។

ប៊ុនថន: ចុះភូមិឃុំហ្នឹងមានតាំងពីមុនពូចូលមក ឬក៏ក្រោយមកទើបតែដាក់រៀបចំទេពូ ជាភូមិ ជាឃុំជាស្រុកអញ្ចឹង?

សែម: ៩០ប៉ុន្មានទេបើតាមខ្ញុំចាំ ដូចជាភ្លេចហើយ បង្កើតស្រុកវាលវែង បង្កើតស្រុកបង្កើតភូមិហ្នឹងដូចជា៩១ ខ្ញុំដូចជាអត់សូវចាំទេ ដូចជាភ្លេចហើយ អាហ្នឹងគេដាក់តើ តែខ្ញុំនៅហ្នឹងនៅមុនហ្នឹងទៀត តែគ្រាន់តែគេប្រកាសបង្កើតក្នុងរចនាសម្ព័ន្ធភូមិឃុំហ្នឹងខ្ញុំអត់បានចាំ តែត្រូវបង្កើតហើយ ព្រោះក្នុងរចនាហ្នឹងវាយើងត្រូវកើត ថ្មរដាក៏អញ្ចឹងដែរ ការពិតមេឃុំថ្មរដាគេតែងតែជួបហ្នឹងសម្ដេចហ៊ុន សែន គាត់ថាអនុញ្ញាតិឲ្យនៅ ប៉ុន្តែកុំតែបានប្រជាជនហ្នឹងកុំអីថៃឡើងមកយូណាស់ហើយ តែដោយប្រជាជនហ្នឹងមិនមែនប្រជាជនសុទ្ធសាតទេ មានទ័ពអតីតខ្មែរក្រហមចាស់ អញ្ចឹងគាត់នៅនោះគាត់ដឹងដីហ្នឹង គាត់ទៅឈរនៅហ្នឹងអញ្ចឹងបានថៃអត់ហ៊ានចូលមកទេ អញ្ចឹងបាននៅទាល់រាល់ថ្ងៃទៅបង្កើតទៅជារចនាសម្ព័ន្ធទៅ បង្កើតជាស្រុកអញ្ចឹងទៅ មានភូមិ មានឃុំអញ្ចឹងទៅតគ្នាអញ្ចឹងមក ហើយបានមានភូមិឃុំហើយដល់ពេលអញ្ចឹងអភិបាលស្រុកគាត់ថាអញ្ចេះ យើងដើម្បីការពារទាល់តែយើងធ្វើប្លង់ដីត្រឹមត្រូវទៅ អញ្ចឹងក្នុងហ្នឹងមានភូមិបាលគេចុះមកធ្វើប្លង់ដីយើងធ្វើទៅ ធ្វើបែបបទអីសព្វបែបយ៉ាង លឿនជាងគេខាងក្នុងទៀត គេខាងក្នុងគេអត់ទាន់ធ្វើទេ ដល់ឥឡូវគេកំពុងតែធ្វើ តែនៅនេះអត់ទេ ធ្វើតាំងពីយូហើយ ធ្វើហ្នឹងដូចជា២០០១ ២០០១ហ្នឹងយើងធ្វើប្លង់ដីហើយ ហើយរចនាសម្ព័ន្ធហ្នឹងកើតមុន២០០១ ។

ប៊ុនថន: អញ្ចឹងមានភូមិមានអីគេស្រាប់តាំងពីមុនហ្នឹង?

សែម: បាទ! ភូមិនេះការពិតគេមកស្រាវជ្រាវដែរពីប្រវត្តិរបស់ភូមិ ដើមឡើយនោះគេហៅថាជនជាតិភាគតិចរស់នៅ ដូចឥឡូវគេគ្រាន់កែពាក្យបន្តិច ពីដើមឡើយគេហៅថាខ្ពង់រាបដូចឃុំអញ្ចឹងណា៎ ឃុំហ្នឹងគេហៅតែខ្ពង់រាបទេ តែឥឡូវគេកែពាក្យដាក់ទៅអន្លង់រាបវិញ ឃើញទេពាក្យហ្នឹងវាខុសគ្នាបន្តិច តែវាមិនអីទេឲ្យតែបានរចនាសម្ព័ន្ធហ្នឹងកើន ហើយនេះមុនដំបូងគេដាក់ភូមិគគី ការពិតមូលហេតុមកពីមានដើមគគីវាច្រើន ប៉ុន្តែដល់ក្រោយមកចូលក្នុងរចនាសម្ព័ន្ធគេដាក់ថាភូមិដីក្រហមទៅវិញ ដល់ពេលដាក់ដីក្រហមពួកក្រុមហ៊ុនមួយៗគេគ្រាន់តែឮថាដីក្រហមគេចង់បានប៉ះពាល់ប្រជាជន គេចង់បានដីក្រហម ។

ប៊ុនថន: ហើយដំបូងហ្នឹងមក ពូចុះមកហ្នឹងប្រកបមុខរបរអីដែរ?

សែមៈ ពេលខ្ញុំការអីធម្មតាអញ្ចឹង តែពេលហ្នឹងកាលលក់ឈើហ្នឹងគេបើកអង្ករឲ្យយើងហូប ហើយប្រាក់ខែបើតាមគិតទៅខ្ញុំសាកសួរថៃក្នុងមួយខែគេឲ្យមួយម៉ឺនប្រាំពាន់បាត អ្នកដែលដើរវាស់ដើរអីហ្នឹង ហើយបុគ្គលិកអញ្ចឹងគេឲ្យមកតាម ប៉ុន្តែគេអត់ឲ្យមកបុគ្គលយើងទេ ព្រោះគណៈស្រុកដល់នេះគេបូកសរុបក្នុងមួយឆ្នាំអញ្ចឹងមានលុយទាំងអ្នកធ្វើការងារប៉ុន្មានអីប៉ុន្មាន ពេលវាចេញយកលុយទៅបង់ឲ្យ ម៉េត នៅសំឡូត មានសុទ្ធតែហែរហមឡានអី មានអង្ករក្សវាទៅច្រើនតែសំពត់វែងខ្លីហែរហមលុយហ្នឹងយកទៅឲ្យប្រគល់ឲ្យ ម៉េត ហ្នឹង ។

ប៊ុនថនៈ តែអត់មានបានលើបុគ្គលយើងទេ?

សែមៈ អត់ទេ វាអត់មានឲ្យយើងទេ វាមិនឲ្យតាមសាមាជិកដែលធ្វើការងាររាល់ថ្ងៃហ្នឹង តែក្នុងហ្នឹងគេអត់ឲ្យអត់បាយទេ ការពិតឧទាហរណ៍ថា កន្លះខែទៅបើកអង្ករប៉ុន្មាន ដូចថាមួយគ្រួសារមានគ្នា៥នាក់អញ្ចឹងត្រូវអង្ករប៉ុន្មានគេបើកឲ្យ តែបើរឿងលុយកាក់អីអត់ទេ អត់មានឲ្យយើងទេ ។

ប៊ុនថនៈ អញ្ចឹងពូមកនេះអត់មានប្រកបរបរចំការអីទេ?

សែមៈ រាល់ថ្ងៃធ្វើចំការ ។

ប៊ុនថនៈ ចុះពូ សួរដូចពីមុនពេលសាមារណកម្មហើយក្រោយមក ដូចថាការរស់នៅហើយជីវភាពដូចថាខុសប្លែកគ្នាយ៉ាងម៉េចដែរលោកពូ?

សែមៈ ប្លែកពីមុនមកបានន័យថាយើងរស់នៅយើងធ្វើការងារក៏ធ្វើ បើមិនធ្វើការងារក៏នៅតែមានរបប ព្រោះរបបពេលនោះការពិតគេអត់ឲ្យមានលុយកាក់អីទេ គេបើកឲ្យហូងឲ្យតែមានមនុស្សគេបើកឲ្យប្រចាំថ្ងៃឲ្យហូបហ្នង ព្រោះមានខាងភស្តុភាគេ ឬក៏ប៉ុល ពត ឧទាហរណ៍ថាម៉ាអង្គភាពនោះមានគ្នាចំនួនប៉ុន្មានអញ្ចឹង អញ្ចឹងគេបើកឲ្យមនុស្សទាំងអស់ហ្នឹងហូប តាំងពីប្រហុក ប៊ីចេង ស្ករ ត្រីខអីហ្នឹងបើកទាំងអស់ តែដល់ក្រោយមកដែលយើងវៃចេញមកបានន័យថាយើងសាមារណកម្ម ភាគច្រើនអ្នកខ្លះជាប់ខាងទាហាន តែខ្ញុំធុញទ្រាន់ ខ្ញុំអ៊ំមិនអីទេ មិនបាច់ជាប់ខាងទាហានជាប់អីទេ ឥឡូវយើងរកស៊ីដាំស្រូវធម្មតា ទាហានអីទាហានទៅបានខ្ញុំផាត់ចោលខាង៣០-៤០ឆ្នាំអត់មានធ្វើអីខ្ញុំខឹង ខ្ញុំអត់មានឲ្យទៅពិនិត្យមុខទាហានទេធ្វើអីក៏ខ្ញុំអត់ទៅដែរ ខ្ញុំនៅតែផ្ទះហ្នឹង ដល់ក្រោយហ្នឹងបានជួយការងារខាងឃុំអីតិចៗអញ្ចឹងទៅ ធ្វើការងារក្នុងឃុំតិចៗអញ្ចឹងទៅ ។

ប៊ុនថនៈ មុនហ្នឹងខ្ញុំអត់មានបានសួរឈ្មោះពូ តើពូឈ្មោះអីដែរ?

សែមៈ ខ្ញុំឈ្មោះ សែម ។

ប៊ុនថនៈ ស្អី សែម?

សែមៈ សួន សែម ។

ប៊ុនថនៈ ពូអាយុប៉ុន្មានហើយ?

សែមៈ បើគិតឥឡូវ៦០ហើយ កើតឆ្នាំ១៩៥២ ។

ប៊ុនថនៈ ពូមានភូមិកំណើតនៅណាដែរ?

សែមៈ ខ្ញុំនៅភូមិឈើទាល ឃុំផ្តៅជុំ ស្រុកជើងព្រៃ អាហ្នឹងស្រុកឪពុកខ្ញុំ តែម្តាយខ្ញុំនៅទន្លេ កង ហ្នឹង ខ្ញុំកើតអាកាកោង ។

ប៊ុនថនៈ ហើយសព្វថ្ងៃមានកូនប៉ុន្មាននាក់?

សែមៈ មាន៥នាក់ ។

ប៊ុនថនៈ ហើយនៅមានសំនួរមួយទៀត ខ្ញុំចង់សួរចុងក្រោយសួរពីយោបល់របស់ពូឲ្យផ្ទាល់ សព្វថ្ងៃ យើងមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ដែលមានរាជរដ្ឋាភិបាលខ្មែរជាមួយ អង្គការសហប្រជាជាតិបង្កើតជាតុលាការហ្នឹង ហើយរាល់ថ្ងៃមានចាប់មេដឹកនាំ៥ទាំងឌុច តែ ឌុច បានកាត់ទោសរួចហើយមានអៀង សារី មានខៀវ សំផន មានអៀង ធារិទ្ធ ហើយនួន ជា កំពុងឃុំឃាំងហើយរង់ចាំថ្ងៃកាត់ទោស ហ្នឹងពូយល់យ៉ាងម៉េចដែរចំពោះការ កាត់ទោសមេដឹកនាំទាំងនេះ?

សែមៈ ចំពោះបញ្ហានេះ ដូចទស្សនៈរបស់ខ្ញុំដែលខ្ញុំបានជម្រាបហើយ ការពិតខ្ញុំក៏ជាអ្នករងគ្រោះ ដូចប្រជាជនទូទៅដែរ បើសិនជារកឃើញករណីថាគាត់បានប្រព្រឹត្តអីមួយ បានន័យថា ទោសនេះមានន័យថាបើសិនជាឥឡូវមិនមានការកាត់ទោសថ្ងៃមុខថ្ងៃក្រោយអ្នកដឹកនាំបេះ តែប្រព្រឹត្តិតទៅទៀត វាទម្លាប់ទៅអញ្ចឹង បើមានតុលាការកាត់ទោសខ្ញុំអត់មានតូចចិត្ត យ៉ាងម៉េចទេការពិត ទោះបីខ្ញុំនៅអតីតខ្មែរក្រហមដែរ តែគ្រាន់ថាខ្ញុំក៏ជាអ្នករងគ្រោះដូចតែ បងប្អូនបាត់ម៉ែបាត់ឪដូចគ្នាអញ្ចឹងណ៎ានៅក្នុងសម័យនោះ តែការពិតភស្តុតាងហ្នឹងវាមិនដឹង ជាអ្នកណាសអ្នកណាខ្មៅទេ ខ្ញុំពិបាករកណាស់ព្រោះវាអត់ដឹងអញ្ចឹងណ៎ា អញ្ចឹងបើសិនជា បង្កើតជាតុលាការកាត់ទោសនោះរកករណីឃើញខ្ញុំអត់មានតូចចិត្តទេ សប្បាយចិត្តដែរ ។

ប៊ុនថនៈ ចុះពូកាលជំនាន់នោះដូច អៀង ធារិទ្ធ អីពូស្គាល់ដែរ?

សែមៈ ស្គាល់ ការពិតឈ្មោះគាត់ យាយភា ទេ កាលមុនមកការពិតយាយអៀង ធារិទ្ធ ហើយ នឹងប្រពន្ធប៉ុល ពត ហ្នឹងបងប្អូនគ្នាបង្កើត ហើយប៉ុល ពត នឹងអៀង សារី ហ្នឹងការពិតជា សិស្សរួមថ្នាក់ ការពិតគាត់នៅកម្ពុជាក្រោមទេស្រុកកំណើតរបស់គាត់ ប៉ុន្តែដល់ក្រោយមក បងហ្នឹងយកតាប៉ុល ពត ហើយប្អូនហ្នឹងក៏យកតាអៀង សារី ក្រោយមកបានន័យថាដាក់

ត្រកូលប្ដីឈ្មោះ អៀង ធារិទ្ធ គេកែទៅជាអញ្ចឹងវិញ យកត្រកូលប្ដីដាក់ណា៎ តែការពិតគាត់ឈ្មោះ យាយភា ទេ ។

ប៊ុនថន: តែដែលជួបគាត់ទេពូកាលជំនាន់ហ្នឹង?

សែម: កាលនៅព្រំដែនអាសារជួប តែឥឡូវមិនដែលបានជួបទេព្រោះមិនអាចទៅវិញទៅមកបានទេ កាលនៅព្រំដែនអាសារជួបព្រោះការពិតអ្វីៗដូចជាការគ្រុន ការឈឺគេច្រើនមកសម្រាកពេទ្យទាំងអស់គ្នា ប្រពន្ធតាន្ទន ជា ប្រពន្ធតាខៀវ សំផន ប្រពន្ធប៉ុល ពត ណាណីក៏ត្រូវមកសម្រាកពេទ្យហ្នឹងដែរ ។

ប៊ុនថន: ពេទ្យណាវិញពូ?

សែម: ពេទ្យស្រីៗខ្ញុំហ្នឹង ពេទ្យកន្លែងភឿន កន្លែងយាយភា ហ្នឹង ពេទ្យហ្នឹងវាមានច្រើនផ្នែក ការពិតកាលនោះគាត់ទទួលពេទ្យរដ្ឋមន្ត្រីខាងសង្គមកិច្ច តែដល់ពេទ្យនោះវាមានពេទ្យរដ្ឋ មានពេទ្យកងពលអញ្ចឹង ហើយស្រីៗខ្ញុំការពិតពេទ្យកន្លែងតាភឿន ហ្នឹងឯង ។

ប៊ុនថន: គាត់ខាងសង្គមកិច្ចមែន ឬក៏កងពល?

សែម: ពេទ្យនេះហ្នឹងហ្នង ពេទ្យរបស់ យាយភា បង្កើតអញ្ចឹងហ្នងជុំវិញកន្លែងគាត់ ។

ប៊ុនថន: អញ្ចឹងខ្ញុំដូចជាអត់មានអីសួរលោកពូទៀតទេ តើលោកពូមានអីចង់បន្ថែមទេ?

សែម: បាទ! ខ្ញុំអត់មានអីបន្ថែមទេ គ្រាន់ថាការកាត់ទោសនេះមានន័យ បើតាមខ្ញុំយល់ទៅដើម្បីរកយុត្តិធម៌ជូនអ្នករងគ្រោះ តែខ្ញុំសូមសំណូមពរបើសិនជារកករណីឃើញអាហ្នឹងទៅតាមទោសកំហុសរបស់គាត់ទៅចុះ អាហ្នឹងមិនដឹងធ្វើម៉េច តែតុលាការខ្ញុំឆ្ងល់ដែរ ការពិតបើសិនជាការកាត់ទោសនោះចំពោះតែអ្នកដឹកនាំ ព្រោះការពិតតុលាការនេះបើតាមខ្ញុំយល់យើងនឹងកើតក្រោយប្រតិការណ៍ដែលមានហើយ ព្រោះប្រតិការណ៍ហ្នឹងយើងគិតតាំងពីឆ្នាំ៧៥ ដល់ឆ្នាំ៧៩ តែតុលាការហ្នឹងទើបតែកើត អញ្ចឹងបានថាដូចខ្ញុំជម្រាបអញ្ចឹង ដូចខ្ញុំអាយុប៉ុណ្ណឹងអត់មានទឹកឃើញអស់ទេ វាភ្លេចមុខភ្លេចក្រោយ អញ្ចឹងវាពិបាកអារឿងដើរសន្សំភស្តុតាងអាក្តីអីហ្នឹង អាហ្នឹងបើតាមខ្ញុំយល់ណា៎ ។

ប៊ុនថន: អញ្ចឹងបានយើងមានខាងតុលាការត្រូវមានភស្តុតាងអីច្បាស់លាស់ ព្រោះការកាត់ទោសវាមិនមែនតែយុត្តិធម៌សម្រាប់ជនរងគ្រោះទេ តែដូចថាអ្នកជាប់ទោសក៏គាត់ត្រូវការយុត្តិធម៌ដែរ អញ្ចឹងទាំងសងខាងហ្នឹងឲ្យស្មើភាព ដូចលោកពូនិយាយអញ្ចឹងភស្តុតាង អញ្ចឹងលោកពូមានអីចង់បន្ថែមទៀតទេ?

សែម: អត់មានទេ ។

ប៊ុនថន: អញ្ចឹងខ្ញុំអរគុណលោកពូច្រើន ។